# របាយការណ៍
# សិក្ខាសាលាពិគ្រោះយោបល់
# ស្តីពីការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ

លេខាធិការដ្ឋានរេដបូកកម្ពុជា

ថ្ងៃទី៦-៨ ខែកក្កដា ឆ្នាំ២០១៥
ខេត្តសៀមរាប សណ្ឋាគារសុខាល័យអង្គរ



រៀបចំដោយ
លេខាធិការដ្ឋានរេដបូកកម្ពុជា

## សេចក្តីផ្តើម

យុទ្ធសាស្ត្ររេដបូកជាតិ គឺជាឯកសារគោលនយោបាយដ៏សំខាន់មួយដែលផ្តល់នូវទិសដៅយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍សកម្មភាពរេដបូក។ ដូចជាយុទ្ធសាស្ត្រផ្សេងៗទៀតដែរ យុទ្ធសាស្ត្ររេដបូកជាតិ គឺដើម្បីកំណត់នូវ បុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងរៀបចំគោលនយោបាយដ៏សាកសម្ប និងវិធានចាំបាច់មួយចំនួនដើម្បីកាត់បន្ថយនូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលសកម្មភាពទាំងនេះឈានទៅដល់ការវាស់នូវបរិមាណនៃកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអភិរក្ស និងបង្កើនបរិមាណកាបូនដែលផ្ទុកនៅក្នុងព្រៃ។

យោងតាមការសម្រេចរបស់ប្រទេសដែលជាភាគីនៃក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ( UNFCCC) ជាពិសេសនៅក្នុងកិច្ចព្រមព្រៀង ខេនខូន និងក្របខណ្ឌវ៉ស(Warsaw) សម្រាប់រេដបូក យុទ្ធសាស្ត្ររេដបូកជាតិ គឺជាតម្រូវការដំបូងគេបង្អស់សម្រាប់ប្រទេសដែលចង់អនុវត្តន៍រេដបូក ដូចជាប្រទេសកម្ពុជា ដើម្បីឈានដល់ការទទួលបានការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល (Result-based finance) សម្រាប់អនុវត្តន៍គោលនយោបាយ និងវិធានរេដបូក។ តម្រូវការសំខាន់ផ្សេងទៀតសម្រាប់ការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល រួមទាំង ឯកសារជាតិស្តីពីប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ មក្រិតបំភាយយោង និងប្រព័ន្ធព័ត៌មានសុវត្ថិភាពរេដបូក។

គោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺអោយមានយុទ្ធសាស្ត្ររេដបូកមួយដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន បន្ទាប់មកនឹងមានការទទួលស្គាល់ពីទីស្តីការគណៈរដ្ឋមន្ត្រី មុនពេលកិច្ចប្រជុំប្រទេសជាភាគី នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងខែធ្នូ ឆ្នាំ២០១៥ខាងមុខនេះ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ ពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ ត្រូវបានរៀបចំឡើង។ ឯកសារនេះបានផ្ញើជូនក្រុមអ្នកជំនាញការផ្នែករេដបូកដើម្បីពិនិត្យ និងផ្តល់យោបល់កែសម្រួល ដែលសមាជិកក្រុមអ្នកជំនាញមានចំនួន ១១នាក់ (ទាំងអ្នកជំនាញជាតិ និងអន្តរជាតិ)។ យោបល់ និងអនុសាសន៍ដែលបានផ្តល់ដោយក្រុមអ្នកជំនាញការត្រូវបានប្រមូល និងបន្ថែមពីនេះទៀតពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ក៏បានចែករំលែកដល់អ្នកពាក់ព័ន្ធសំខាន់ទៀត ជាពិសេសមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ នៅដំណាច់ខែមីនា ឆ្នាំ២០១៥ យោបល់ទាំងអស់ដែលបានផ្តល់ទៅលើពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ ត្រូវបានប្រមូលពីអ្នកជំនាញផ្នែករេដបូក និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ និងទីប្រឹក្សាបានធ្វើការកែសម្រួលដែលបានរៀបចំពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិលើកទី២ បន្ថែមពីលើនេះ ប្រវត្តិឯកសារ បានរៀបចំទន្ទឹមគ្នានឹងពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិដែរ។ ប្រវត្តិឯកសារត្រូវបានគេរៀបចំគឺដើម្បីចងក្រងនូវយោបល់របស់អ្នកពាក់ព័ន្ធ និងចំណុចសំខាន់ៗដែលបានឆ្លើយតបចំពោះអនុសាសន៍ និងយោបល់ទាំងនោះ។

យោងតាមកិច្ចពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ និងផែនការរបស់ប្រទេសកម្ពុជាដើម្បីអោយមានពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយមុនកិច្ចប្រជុំភាគីនៅទីក្រុងប៉ារីស គឺរំពឹងថាពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិទី៣ នៅដំណាច់ខែមិថុនា និង ពង្រៀងយុទ្ធសាស្ត្របូកជាតិទី៤ និងត្រូវរួចរាល់នៅក្នុងខែកក្កដា និងពង្រៀងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយនៅក្នុងខែសីហា ឆ្នាំ២០១៥។

នាខែឧសភា និងខែសីហា ឆ្នាំ២០១៥ យុទ្ធសាស្ត្ររេដបូកជាតិ និងចំណុចដែលត្រូវគូសបញ្ជាក់នៅក្នុងឯកសារប្រវត្តិ នឹងត្រូវយកមកពិគ្រោះយោបល់ជាមួយក្រុមអ្នកពាក់ព័ន្ធ ដូចជា ក្រុមការងាររេដបូកកម្ពុជា ក្រុមកិច្ចប្រឹក្សា

យោបល់ ក្រុមការងារបច្ចេកទេស (ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ចែករំលែកផលប្រយោជន៍ ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ និងក្រុមការងារអនុវត្តគំរូ) ក្រុមការងារយេនឌ័រ និងអ្នកពាក់ព័ន្ធទូទាំងប្រទេស។ កិច្ចប្រជុំពិគ្រោះយោបល់នេះនឹងប្រើប្រាស់ជាវេទិកាសម្រាប់អ្នកពាក់ព័ន្ធនានាដើម្បីផ្តល់ជំនាញបច្ចេកទេសរបស់ពួកគេ និងក្តីបារម្មណ៍របស់ពួកគេទៅលើយុទ្ធសាស្រ្ត។ សូមគូសបញ្ជាក់ផងដែររាល់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីយុទ្ធសាស្រ្តរេដបូកជាតិនឹងត្រូវចងក្រងជាឯកសារដែលនឹងគូសបង្ហាញនៅក្នុងឯកសារប្រវត្តិ ដើម្បីធានាថាដំណើការរៀបចំយុទ្ធសាស្រ្តរេដបូកជាតិ គឺតម្លាភាព និងមានការទទួលខុសត្រូវ។

## គោលបំណង

គោលបំណងជាក់លាក់សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់នឹងផ្អែកទៅលើពង្រៀងឯកសារនីមួយៗដែលនឹងត្រូវពិគ្រោះយោបល់។ ជាទូទៅកិច្ចប្រជុំពិគ្រោះយោបល់យុទ្ធសាស្រ្តរេដបូកជាតិនីមួយៗគឺមានគោលបំណង៖

- បង្ហាញពីស្ថានភាពនៃការរៀបចំយុទ្ធសាស្រ្តរេដបូកជាតិ ដំណើការ និងគូសបញ្ជាក់នូវធាតុចូលដែលជាតម្រូវការ ឬ ការសម្រេចចិត្ត (ឧទាហរណ៍ ទំហំនៃការអនុវត្តរេដបូក, បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ , គោលនយោបាយ និងវិធាន, ។ល។)

- ប្រមូលធាតុដែលមានលក្ខណៈបច្ចេកទេស និងក្តីបារម្មណ៍ទូទៅពីអ្នកចូលរួម និងអ្នកបច្ចេកទេសដែលនឹងបន្ទាប់មកទៀតនឹងដាក់បញ្ចូលទៅក្នុងពង្រៀងយុទ្ធសាស្រ្ត។

- កំណត់តម្រូវការដែលជាធាតុចូលបន្ថែមទៀត ដើម្បីធ្វើការកែសម្រួលយុទ្ធសាស្រ្តពង្រៀង។

ថ្លែងសុន្ទរកថាបើកប្រធានអង្គប្រជុំរបស់ **លោក អ៊ុក វិបុល** ប្រធាននាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល

- យុទ្ធសាស្រ្តរេដបូកជាតិគឺជាឯកសារគោលនយោបាយដ៏សំខាន់មួយដែលផ្តល់នូវទិសដៅយុទ្ធសាស្រ្ត និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍សកម្មភាពរេដបូក។ ដូចជាយុទ្ធសាស្រ្តផ្សេងៗទៀតដែរ យុទ្ធសាស្រ្តរេដបូកជាតិ គឺដើម្បីកំណត់នូវ បុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងរៀបចំគោលនយោបាយដ៏សាកសម្ប និងវិធានចាំបាច់មួយចំនួនដើម្បីកាត់បន្ថយ នូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលសកម្មភាព ទាំងនេះឈានទៅដល់ការវាស់នូវបរិមាណ នៃកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអភិរក្ស និងបង្កើនបរិមាណការបូនដែលផ្ទុកនៅក្នុងព្រៃ ។

- កិច្ចប្រជុំពិគ្រោះយោបល់នេះនឹងប្រើប្រាស់ជាវេទិកាសម្រាប់អ្នកពាក់ព័ន្ធនានាដើម្បីផ្តល់ជំនាញបច្ចេកទេសរបស់ពួកគេ និងក្តីបារម្មណ៍របស់ពួកគេទៅលើយុទ្ធសាស្រ្តរេដបូកជាតិនេះ។ សូមគូសបញ្ជាក់ផង ដែររាល់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីយុទ្ធសាស្រ្តរេដបូកជាតិនឹងត្រូវចងក្រងជាឯកសារដែលនឹង

បង្ហាញនៅក្នុងឯកសារប្រវត្តិ ដើម្បីធានាថាដំណើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិមានតម្លាភាព និងការទទួលខុសត្រូវ។

- សេចក្តីព្រាងយុទ្ធសាស្ត្រ រេដបូកជាតិដោយផ្តោតទៅលើជំពូកទី១ ដល់ជំពូកទី៤ ដោយសង្កត់ធ្ងន់ទៅលើ ការជ្រើសរើសសកម្មភាព ក្នុងការអនុវត្ត ក្រុមយន្តការរេដបូក ទំហំនៃការអនុវត្ត បុព្វហេតុនៃការបាត់បង់ព្រៃឈើ និង ការរេចរឹលព្រៃឈើ ក្រុមការងារបច្ចេកទេស ក៏បានស្វែងរកនូវ គោលនយោបាយ និងវិធាន ដើម្បីដោះស្រាយបញ្ហា ការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ដែលក្រុមការងារអ្នកសម្របសម្រួលនឹងបង្ហាញនូវលទ្ធផលសង្ខេបនារបៀបវារៈបន្ទាប់។

- នៅក្នុងកិច្ចប្រជុំនេះ យើងទាំងអស់គ្នានឹងពិភាក្សានូវ ជំពូកបន្តទៀតដែលមាននៅក្នុងយុទ្ធសាស្ត្រ រេដបូកជាតិ ដូចជា ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ការគ្រប់គ្រងមូលនិធិរេដបូកជាតិ ប្រព័ន្ធត្រួតពិនិត្យ ព្រៃឈើជាតិ កម្រិតបំភាយយោងព្រៃឈើ ដែលជាផ្នែកដ៏សំខាន់ក្នុងការជម្រុញអោយការអនុវត្តយន្តការ រេដបូកទទួលបានជោគជ័យ និងឈានដល់ការទទួលបានការទូទាត់សងផ្អែកលើលទ្ធផល( Result based finance) ក្រោមយន្តការអង្គការសហប្រជាជាតិ UNFCCC។

- បន្ទាប់ពីការពិគ្រោះយោបល់នេះនឹងរៀបរៀងចប់សព្វគ្រប់ ក្រុមការងារបច្ចេកទេស នឹងរៀបចំឯកសាររេដបូកជាតិនេះអោយក្លាយជាសេចក្តីព្រាងទី៣ នឹងដាក់ចូល កិច្ចពិភាក្សា ក្នុងចំណោម អ្នកសម្រេច ចិត្តផ្នែកគោលនយោបាយ មុនដាក់អោយមានការពិគ្រោះយោបល់ជាសាធារណៈនៅថ្នាក់ ក្រោមជាតិ និងថ្នាក់ជាតិដែលជាសេចក្តីព្រាងចុងក្រោយមុនដាក់ស្នើសុំការសម្រេចពី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន។ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការបង្ហាញយុទ្ធសាស្ត្ររេដបូកមួយ នេះនៅ ក្នុងកិច្ចប្រជុំប្រទេសជាភាគី នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងខែធ្នូ ឆ្នាំ២០១៥ខាងមុខនេះ។

- លេខាធិការដ្ឋាន REDD+ កម្ពុជា ក្រោមគួសបង្ហាញពី ក្រុមការងារ REDD+ កម្ពុជា បានសហការជាមួយ ក្រុមទីប្រឹក្សាបច្ចេកទេស បានរៀបចំសិក្ខាសាលាពិគ្រោះ យោបល់ក្នុងក្របខណ្ឌបច្ចេកទេសនេះឡើង ។ លទ្ធផលនៃសិក្ខាសាលានេះនឹងដាក់បញ្ចូល ទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិក្នុងសេចក្តីព្រាង យុទ្ធសាស្ត្រជាតិលើកទី៣។

- កិច្ចប្រជុំពិគ្រោះយោបល់នេះនឹងប្រើប្រាស់ជាវេទិកាសម្រាប់អ្នកពាក់ព័ន្ធនានាដើម្បីផ្តល់ជំនាញបច្ចេកទេសរបស់ពួកគេ និងក្តីបារម្មណ៍របស់ពួកគេទៅលើយុទ្ធសាស្ត្ររេដបូកជាតិនេះ។ សូមគូសបញ្ជាក់ផងដែរពាល់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីយុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវចងក្រងជាឯកសារដែលនឹងគូសបង្ហាញនៅក្នុងឯកសារប្រវត្តិ ដើម្បីធានាថាដំណើការរៀបចំយុទ្ធសាស្ត្រ រេដបូកជាតិ មានតម្លាភាព និង ការទទួលខុសត្រូវ។

**<u>បទបង្ហាញ ស្តីពី សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ(ជំពូកទី១ - ជំពូកទី៤) ដោយ លោក ឈុន ឌីលុច និងក្រុមការងារទ្រីក្សាបច្ចេកទេសនឹងបង្ហាញព័ត៌មានលំអិតនៃជំពូកនីមួយៗ ( ជំពូកទី៥ ដល់ទី៦ ) នៃ យុទ្ធសាស្ត្ររេដបូកជាតិ៖</u>**

**<u>( សូមជូនភ្ជាប់បទបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី III)</u>**

- ការគ្រប់គ្រងហិរញ្ញប្បទានរេដបូកជាតិ
- ប្រព័ន្ធព័ត៌មានស្តីពី ប្រព័ន្ធធានាសុវត្ថិភាពរេដបូក
- កម្រិតបំភាយយោងព្រៃឈើ
- ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ

**<u>សំនួរ និងចម្លើយ៖</u>**

**លោក ឡុង រតនៈកុមា៖** គួរបញ្ជាក់ និងកែសម្រួលពីចំណុចដែលបានបញ្ជាក់ថា *<u>ការកាប់រានដីខុសច្បាប់</u>* ស្ថិតនៅក្រោមផ្នែកនៃការរេចរឹលព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពដែលនៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្រនេះ ការស្តារព្រៃឈើ និងការដាំឈើឡើងវិញ មិនគួរជាសកម្មភាពដោះស្រាយការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព គួរតែជាការដកហូត និងប្រើប្រាស់ឈើប្រកបដោយនិរន្តភាព។ ភាគដីដែលស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច បានកាត់ចេញពីដីសាធារណៈរបស់រដ្ឋ តាមរយៈការធ្វើអនុប្រយោគ ដូចនេះរដ្ឋបាលព្រៃឈើមិនមានសិទ្ធិក្នុងការគ្រប់គ្រងដីទាំងនេះទេ ម្យ៉ាងទៀតរដ្ឋាភិបាលក៏មានយុទ្ធសាស្ត្រនៅក្នុងការគ្រប់គ្រងដីទាំងនេះដែរ។

**លោក ហុង គីមហ៊ាន៖** ការកំណត់គោលដៅរក្សាគម្របព្រៃអោយបាន ៦០ភាគរយរបស់រាជរដ្ឋាភិបាលនឹងមិនមានការកែប្រែទេ។ ចំពោះសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច នោះគឺរាជរដ្ឋាភិបាលបានបំលែងដីទាំងនោះពីដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ ដូចនេះ ការស្តារព្រៃឈើ និងដាំឈើលើដីដែលរដ្ឋបានដកហូតពីសម្បទានទាំងនេះប្រព្រឹត្តទៅដោយរបៀបណា? តើនឹងត្រូវបំលែងដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋវិទេ?

ជារៀងរាល់ឆ្នាំចំនួនប្រជាជនមានការកើនឡើង ដូចនេះនឹងត្រូវការបម្រុងទុកសម្រាប់ពួកគេ ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម និងសំណង់មានទិន្នន័យពីកំណើនប្រជាជន ដូចនេះគួរតែដឹងថាតើត្រូវការដីចំនួនប៉ុន្មានទៀតសម្រាប់ការកើនឡើងចំនួនប្រជាជននាពេលខាងមុខ។ ចំពោះការអនុវត្តរេដបូក គួរតែមានពីរគំរូ ទី១ការអនុវត្តនៅក្នុងតំបន់ដែលជាដីសាសាធារណៈរបស់រដ្ឋ និងទី២ការអនុវត្តនៅក្នុងដីឯកជនរបស់រដ្ឋ។

**លោក ឈិត ឈន៖** ចំពោះ ការអនុវត្តរេដបូក គឺធ្វើយ៉ាងណារក្សាអោយបានកាស្តុក កាបូនអោយបានច្រើន ជាក់ស្តែងនាពេលបច្ចុប្បន្ន ព្រៃឈើបានកំពុងបាត់បង់យ៉ាងខ្លាំងតើការអនុវត្តរេដបូកអាចជួយទប់ ស្កាត់ការបាត់បង់ព្រៃឈើ

ទាំងនេះបានរឺទេ? តើតាមយន្តការណាមួយ? ជាឧទាហរណ៍ នៅក្នុងតំបន់ព្រៃឡង់មានការបាត់បង់ព្រៃឈើយ៉ាងខ្លាំងប្រសិនបើយើងរងចាំដល់ឆ្នាំ២០២០ នោះនឹងមិនមានព្រៃឈើសេសសល់ឡើយ។

**លោក សុខ ពិសិដ្ឋ៖** នៅក្នុងទស្សនៈវិស័យគួរតែឆ្លុះបញ្ចាំងពីការចូលរួមរបស់ស្ត្រី " *ការបង្កើនសមត្ថភាពដល់បុរស និងស្ត្រី នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ* " ។ ចំពោះផ្ទៃដីដែលរាជរដ្ឋាភិបាលបានដកហូតចេញពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចតើដីទាំងនេះនឹងគ្រប់គ្រងដោយរបៀបណា? ប្រសិនបើគ្មានយន្តការគ្រប់គ្រងច្បាស់លាស់នោះទេវានឹងអាច បាត់បង់។

**លោក អ៊ុយ ជីង៖** នៅក្នុងយុទ្ធសាស្ត្រនេះ គួរតែបញ្ជាក់ថា តើមានដីព្រៃដែលរេចរឹលចំនួនប៉ុន្មានហិកតា? តើដីព្រៃចំនួនប៉ុន្មានដែលបានកាប់រានដោយប្រជាជន?ដីព្រៃប៉ុន្មានដែលបានផ្តល់អោយសម្បទានដីសេដ្ឋកិច្ច? ជាបទពិសោធន៍ ស្ថាប័នហិរញ្ញវត្ថុមួយចំនួនបានផ្តល់ប្រាក់កម្ចី ដល់អ្នកកាប់រានដីព្រៃខុសច្បាប់ នឹងទិញរណាយន្តខុសច្បាប់ នេះបញ្ជាក់ថាវិស័យឯកជនមិនបានជួយរាជរដ្ឋាភិបាលនៅក្នុងការទប់ស្កាត់សការបាត់បង់ព្រៃឈើឡើយ អាជ្ញាធរមូលដ្ឋានបានចេញលិខិតបញ្ជាក់ចំពោះ ដីដែលបានកាប់រានខុសច្បាប់ និងមិនមានបញ្ជាក់ពីការដាក់ពិន័យដល់ក្រុមហ៊ុនសម្បទានដីណាដែលអនុវត្តន៍ខុសច្បាប់ និង ក្រុមហ៊ុនសម្បទានដីដែលបានដកហូតមកវិញ។

**លោក ឡាវ សេដ្ឋាផល៖** ទាក់ទងនឹងការបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងថយចុះនៃព្រៃឈើនេះ គឺ យើងទទួលស្គាល់ថាមាន ការខ្វះខាតនៅក្នុងការគ្រប់គ្រង។ ដូចបានលើកឡើង ទាក់ទងនឹងដីដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ជាឧទាហរណ៍ សម្បទានដីសេដ្ឋកិច្ចមួយនៅក្នុងខេត្តកំពង់ធំ រដ្ឋបានដកហូត និងពិន័យអោយក្រុមហ៊ុនធ្វើកាដាំកូនឈើសងឡើងវិញ។ យើងក៏ទទួលស្គាល់ថានៅមានភាពខ្វះខាតក្នុងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ធនធានមនុស្ស និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលថ្នាក់ជាតិគួរពិចារណា ជាក់ស្តែងគ្រាន់តែរាជរដ្ឋាភិបាលមានគម្រោងសាងសង់ផ្លូវពី កំពង់ស្រឡៅ ខេត្តព្រះវិហារ ទៅព្រំដែនឡាវ ព្រៃ និងដីព្រៃដែលនៅជាប់ផ្លូវត្រូវបានកាប់រានធ្វើកម្មសិទ្ធិ។ ចំពោះ ការប្រមូលអុសសម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារដោយសហគមន៍មូលដ្ឋានគឺមិនមែនជាបញ្ហាទេ វាមិនមានផលប៉ះពាល់ដល់ព្រៃឈើទេ ប៉ុន្តែការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ រឺបម្លែងដីព្រៃជាដីប្រើប្រាស់ផ្សេងៗគឺជាបញ្ហាព្រោះនាពេលអនាគតនឹងមិនមានដីសម្រាប់ស្តារព្រៃឈើឡើងវិញឡើយ។

**ឯកឧត្តម ជៀម ប៉េអា៖** ចំពោះ សម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ចវាជាលំបាកកសម្រាប់រាជរដ្ឋាភិបាលក្នុងការអនុម័តយុទ្ធសាស្ត្រវេដបូកជាតិមួយនេះ ប្រសិនបើយើងថា ការបាត់បង់ព្រៃឈើចេញមកពីសម្បទានដីសង្គមកិច្ច។ រាជរដ្ឋាភិបាលបានធ្វើអនុប្រយោគដីទាំងនេះជាដីឯកជនរបស់រដ្ឋរួចហើយ ហើយបានផ្តល់ សិទ្ធិដល់គណៈអភិបាលខេត្តក្នុងការចាត់ចែងក្នុងការបែងចេកដីទាំងនេះ ហើយដីទាំងនេះមិនមែនជាដីព្រៃទេ។ ចំពោះអនុក្រឹត្សលេខ ១៩ គឺក្នុងគោលបំណងធ្វើការបែងចែកដីដល់អ្នកគ្មានដី និងអ្នកខ្វះដីដែលមានជីវភាពក្រីក្រ ហើយក្រសួងមហាផ្ទៃមិនមានផែនការពង្រីកភូមិឡើយ រឺបង្កើតភូមិថ្មីដែរ ដូចនេះខ្ញុំសូមស្នើដកចំណុចនេះចេញ។ តែប្រសិនបើសហគមន៍មួយមានគ្រួសាររស់នៅច្រើនជាង ២៥០គ្រួសារបានកំពុងប្រើប្រាស់ដីដែរអនុម័តដោយរាជរដ្ឋាភិបាល និងមានការស្នើសុំពីអាជ្ញាធរដែនដីដែលរស់នៅតំបន់នោះក្រសួងមហាផ្ទៃនឹងចុះពិចារណាធ្វើការចុះបញ្ជី នេះក្នុង

គោលបំណងធ្វើការបែងចែកមូលនិធិអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅច្បាស់ លាស ក្នុងការគ្រប់គ្រងសម្បទានដីសង្គមកិច្ច។ សម្បទានដីសង្គមកិច្ចមានពីរកម្រិត ទី១កម្រិតថ្នាក់ក្រោមជាតិ ដែលអាជ្ញាធរឃុំជាអ្នកស្នើសុំ និងទី២សម្រាប់ថ្នាក់ជាតិដែលមានក្រសួងពាក់ព័ន្ធនៅជាគណៈកម្មការ។ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកធ្វើការបែងចែកដី។ ជាក់ស្តែង ១០ភាគរយនៃសម្បទានដីសង្គមកិច្ចត្រូវបានរក្សាទុកសម្រាប់អភិរក្សព្រៃឈើ និងជីវចម្រុះ ជាឧទាហរណ៍ គម្រោង LASAD យើងបានផ្តល់ដីប្រមាណជា ១៦០០០ហិកតា ដែលជាដីមិនមានព្រៃ។ រាល់ការផ្តល់សម្បទានដីសង្គមកិច្ច រដ្ឋបាលព្រៃឈើជាអ្នកធ្វើការវាយតម្លៃ និងបញ្ជាក់ថាដីនោះគួរជាសម្បទានដីសង្គមកិច្ចឬមិនគួរ ពួកគេជាអ្នកធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម។ ជាសន្និដ្ឋានរាល់ដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺមានការវាយតម្លៃជាមុន។

**លោក ឡាវ សេដ្ឋាផល៖** រដ្ឋាភិបាលបានផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ច តាំងពីឆ្នាំ២០១២។ សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចមានជាបពាក់ព័ន្ធនឹងការបាត់បង់ និងថយចុះនៃព្រៃឈើ ប៉ុន្តែយើងគួរប្រើភាពពន្យល់អោយសមស្រប។

**បណ្ឌិត កែវ អូម៉ាលីស្ស៖**

- គោលបំណងនៃការអនុវត្តរេដបូក គឺ ចង់កាត់បន្ថយការថយចុះនៃព្រៃឈើ និងការបាត់បង់ព្រៃឈើ តែមិនមានន័យថា លុបបំបាត់ការបាត់បង់ព្រៃឈើ រឺមិនអនុញ្ញាតអោយមានការប្រមូលផលឈើនោះទេ ដូចនេះហើយទើបមានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព។

- គួរកែសម្រួលគោលបំណង ដែលរក្សាគម្របព្រៃអោយបាន ៦០ភាគរយនៅដំណាច់ឆ្នាំ២០១៥។ គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចអោយបាន ៦-៧ ភាគរយប្រចាំឆ្នាំ រាជរដ្ឋាភិបាលមិនគ្រាន់តែគិតគូរដល់ការអភិវឌ្ឍនោះទេថែមទាំងគិតដល់ការអភិរក្សបរិស្ថានផងដែរ។

- ប្រសិនបើចង់រក្សាគោលដៅនៃការរក្សាគម្របព្រៃឈើអោយបាន ៦០ភាគរយ គួរតែកំណត់ដល់ឆ្នាំ២០២៩ ស្របតាមកម្មវិធីព្រៃឈើជាតិ។ វាមានលក្ខណៈប្រសើរប្រសិនបើយើងអាចដកនូវគោលបំណងនេះចេញពីព្រោះមានវាលក្ខណៈទូលំទូលាយ។

- ចំពោះរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រ៖ យើងបានកំណត់ដល់ឆ្នាំ២០២០ នេះជាពេលដែលសាកសម្បនៅក្នុងសាកល្បងនៃការអនុវត្តគោលនយោបាយ និងវិធាន និងការកសាងសមត្ថភាព ដូចជា NFMS, FREL/REL និងSIS។ បន្ទាប់ពីឆ្នាំ២០២០ យើងអាចនឹងទទួលមូលនិធិម្ចាស់ជំនួយ និងអាចទទួលការទូទាត់សងផ្អែកលើលទ្ធផល។ រាជរដ្ឋាភិបាលប្តេជ្ញានៅក្នុងដោះស្រាយការប្រែប្រួលអាកាសធាតុ ប៉ុន្តែកម្ពុជាមិនមានកាតាព្វកិច្ចនៅក្នុងការកាត់បន្ថយការថយចុះ និងបាត់បង់ព្រៃឈើនោះទេ ពីព្រោះវាមានទំនាក់ទំនង

និងវិស័យផ្សេងៗទៀត ដូចនេះវាចាំបាច់ត្រូវមានការប្តេជ្ញានៅក្នុងការផ្តល់ថវិកពីសំណាក់អន្តរជាតិជាចាំបាច់។

- បុព្វហេតុនៃការបាត់បង់ និងថយចុះនៃព្រៃឈើ៖ នៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្របានលើក (១) សម្បទាន (២)ការរុករានដីព្រៃ (៣)ភ្លើងព្រៃ និង (៤)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ខ្ញុំស្នើដក ភ្លើងព្រៃចេញពីព្រោះយើងមិនមានសមត្ថភាពគ្រប់គ្រងវាបានឡើយ វាជាប្រធានស័គ្គ និងវាមិនមែនជាបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើឡើយ។

- សម្បទាន៖ យើងត្រូវគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ចំពោះគោលនយោបាយសម្បទាននេះពីព្រោះ តំបន់សម្បទានដីសេដ្ឋកិច្ច គឺក្រុមហ៊ុនបានកាប់ព្រៃឈើ និងដាំដើមឈើឡើងវិញ ប៉ុន្តែវានឹងបាត់បង់នូវជីវចម្រុះ និងប្រភពទឹកនៅក្នុងតំបន់ទីជម្រាល។ ភាពខ្វះខាតនៅក្នុងការត្រួតពិនិត្យផែនការមេរបស់ក្រុមហ៊ុនជាបញ្ហា ដូចនេះរាជរដ្ឋាភិបាលបានធ្វើការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ច ប្រសិនបើយើងមានផែនការប្រើប្រាស់ដីច្បាស់លាស់នោះសម្បទានមិនមែនជាបញ្ហា សម្រាប់រេដបូកនោះទេ។

- បុព្វហេតុនៃការថយចុះនៃព្រៃឈើសំខាន់មួយចំនួនទៀត៖ តម្រូវការឈើប្រើប្រាស់ក្នុងស្រុក និងក្រៅស្រុក។ តើមានយន្តការណាមួយនៅក្នុងការដោះស្រាយបញ្ហានេះ?

- **ឈើថាមពល៖** ដូចជា ការផលិតធ្យូង និងអុស នេះមិនត្រឹមតែប្រើប្រាស់នៅក្នុងសហគមន៍ប៉ុណ្ណោះទេ គឺភាគច្រើនសម្រាប់ផ្គត់ផ្គង់ដល់អ្នកទីប្រជុំជន និងទីក្រុង។ ដូចនេះគួរតែមានយន្តការដោះស្រាយបញ្ហានេះ។ នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ គួរគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ក្នុងការគ្រប់គ្រងដូចជា បង្កើនផ្ទៃដីព្រៃការពារ តំបន់ការពារ ការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន។

## កិច្ចពិភាក្សាជាក្រុម ស្តីពី ការកែសម្រួលឡើងវិញនូវបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងចុះនៃព្រៃឈើ និង សកម្មភាព/ផែនគោលនយោបាយ និងវិធានដើម្បីដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងចុះនៃព្រៃឈើ ៖

អ្នកចូលរួមបានបែងចែកជាបួនក្រុម (១)ក្រុមធានាសុវត្ថិភាពរេដបូក (២)ការចែករំលែកផលប្រយោជន៍ (៣)ក្រុម MRV/FREL និង (៤)ក្រុមចែកអនុវត្តគម្រូ ចំពោះក្រុមការងាររេដបូកកម្ពុជា ក្រុមការងារយេនឌ័រ និងក្រុមប្រឹក្សាយោបល់បានចូលរួមជាមួយក្រុមពិភាក្សាទាំងបួន។

**ប្រធានបទ៖** ក្រុមពិភាក្សាពិគ្រោះយោបល់ និងកែសម្រួលលើ *បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើ និង សកម្មភាព/ផែនគោលនយោបាយ និងវិធានដើម្បីដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងចុះនៃព្រៃឈើ* ។ ចំពោះលទ្ធផលយកមកពិគ្រោះយោបល់នេះគឺជាលទ្ធផលដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ ដែលបានប្រព្រឹត្តទៅនាសណ្ឋាគារខ្សាច់មាស ថ្ងៃទី ២០ ដល់ ២១ ខែឧសភា ឆ្នាំ២០១៥ នៃក្រុងព្រះសីហនុ។ ចំពោះលទ្ធផលក្រុមនៃក្រុមពិភាក្សានីមួយៗមានជូនភ្ជាប់នៅក្នុង(ឧបសម្ព័ន្ធ) ក្រុមការងារបានធ្វើការសង្ខេបនូវលទ្ធផលនៃក្រុមពិភាក្សាទាំងបួនដូចជាខាងក្រុមនៅក្នុងតារាងដូចខាងក្រោម៖

**បុព្វហេតុបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងថយចុះនៃព្រៃឈើនិង សកម្មភាព/ផែនគោលនយោបាយ និងវិធានដើម្បីដោះស្រាយបុព្វហេតុទាំងនេះ**

- ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្ត្រប្រើប្រាស់ដីច្បាស់លាស់
- ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចអោយបានច្បាស់លាស់នៅទីវាល
- បង្កើនប្រសិទ្ធភាពការអនុវត្ត និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩ (សម្បទានដីសង្គមកិច្ច)
- ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP)
- អភិវឌ្ឍ បច្ចេកវិទ្យាត្រួតពិនិត្យ និងតាមដានការប្រែប្រួលការប្រើប្រាស់ដីព្រៃ
- ស្តារព្រៃនៅតំបន់ដីរេចរឹល
- ប្រែក្លាយសម្បទានដីសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និង សហគមន៍នេសាទ
- ប្រែក្លាយសម្បទានដីសេដ្ឋកិច្ចដែលបានដកហូត មកជា តំបន់ការពារ រឺ ព្រៃការពារ
- ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ឈើខុសច្បាប់
- ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ទន្ទ្រានយកដីព្រៃជាកម្មសិទ្ធិ
- បង្កើតចំការឈើសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក
- បង្កើតជម្រើសផ្សេងៗក្នុងការកាត់បន្ថយសំពាធលើការប្រើប្រាស់អុសនិង ធ្យូង

**សំនួរ និងចម្លើយដែលទាក់ទងក្រុមនីមួយៗក្នុងបទបង្ហាញនៃលទ្ធផលនៃក្រុមពិភាក្សាទាំងបួន**

**លោក សៅ វ៉ារី៖**

- ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានរឹបអូសពីក្រុមហ៊ុនឯកជន ថាតើវាអាចប្រែក្លាយជាដីសារណៈរបស់រដ្ឋដោយរបៀបណា និងមិនមានព្រៃដែលនៅសេសសល់លើដីនោះ? យើងអាចធ្វើការចាត់ថ្នាក់ដីព្រៃទាំងនោះឡើងវិញជាដីសាធារណៈរបស់រដ្ឋ មិនចាំបាច់ធ្វើអនុប្រយោគ ឡើយ យើងអាចពិនិត្យមើលនៅក្នុងអនុក្រឹត្យលេខ១៨ និង៤២។ ការធ្វើការចាត់ថ្នាក់ដីសាធារណៈរបស់រដ្ឋ យើងត្រូវធ្វើការចុះបញ្ជីដីនោះជាមួយក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ពីព្រោះការចុះបញ្ជីវាមានសារៈសំខាន់ណាស់។ បន្ទាប់ពីបានធ្វើការចាត់ថ្នាក់ និងចុះបញ្ជីដី យើងអាចធានាបាននូវសុវត្ថិភាពដីទាំនោះ។

- អំពីសម្បទានដី ដែលមានបញ្ជាក់នៅក្នុងច្បាប់ភូមិបាល វាមានលក្ខណៈខុសពីសម្បទានផ្សេងៗទៀត។ សម្បទានដីមានពីរប្រភេទ ទី១ សម្បទានដីសេដ្ឋកិច្ចដែលក្រុមហ៊ុនត្រូវធ្វើការបង់ពន្ធជូនរដ្ឋ និងទី២ សម្បទានដីសង្គមកិច្ច ដែលមិនតម្រូវអោយមានការបង់ប្រាក់ជូនរដ្ឋ នៅអាចអោយអ្នកទទួលបានដីកាន់កាប់ស្របច្បាប់បន្ទាប់ពីបានគ្រប់គ្រងរយៈពេលប្រាំឆ្នាំ សម្បទានដីសង្គមកិច្ចនឹងអាចផ្តល់ដល់ប្រជាពលរដ្ឋក្រីក្រដែលខ្វះដី និងមិនមានដីប្រើប្រាស់ ដែលដំណើរការផ្តល់ដីផ្អែកលើអនុក្រឹត្យលេខ១៩។ តែសម្រាប់សម្បទានដីសេដ្ឋកិច្ចវិញ ក្រុមហ៊ុនគ្រាន់តែមានសិទ្ធិកាន់កាប់ដីនៅក្នុងរយៈ ពេលនៃកិច្ចព្រមព្រៀងប៉ុណ្ណោះ នៅពេលចប់កិច្ចព្រមព្រៀង រដ្ឋតែជាម្ចាស់ដីនោះដដែល តែក្រុមហ៊ុនអាចធ្វើការផ្ទេរសិទ្ធិនៃការគ្រប់គ្រងទៅអ្នកទី៣ដូចមានចែងនៅក្នុងច្បាប់។

- ចំពោះសកម្មភាពដែលបានស្នើនៅក្នុង យុទ្ធសាស្រ្តរេដបូកជាតិ មិនមានបញ្ជាក់ពីការចុះបញ្ជីដីសាធារណៈរបស់រដ្ឋ។ ប្រសិនបើតំបន់ដែលនឹងអនុវត្តរេដបូកនោះមិនបានចុះបញ្ជីនោះពិបាកធានាសុវត្ថិភាពណាស់ អាចទីបំផុតនឹងមានការបាត់បង់ព្រៃឈើ ទាំងអាចបាត់បង់ដីព្រៃថែមទៀត។ ចំពោះការចុះបញ្ជីជាកាតព្វកិច្ចអាជ្ញាធរដែលទទួលសិទ្ធិគ្រប់គ្រងដីនោះ ដូចជាក្រសួងបរិស្ថានគ្រប់គ្រងតំបន់ការពារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់គ្រងតំបន់ព្រៃការពារ សហគមន៍ព្រៃឈើ..។ ជាក់ស្តែងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន បានដាក់តំបន់របស់ខ្លួនចុះបញ្ជីខ្លះហើយ។

**តំណាងសហគមន៍៖** ចំពោះដីសាធារណៈរបស់រដ្ឋ។ នៅពេលដែលរដ្ឋបានដកហូតពីក្រុមហ៊ុន ហើយបានធ្វើចំណាត់ថ្នាក់ឡើងវិញ និងបានចុះបញ្ជី តើ អ្នកណាគេជាអ្នកសម្របសម្រួលរៀបចំ?

**លោក សៅ រ៉ារី៖** ដំណើរការចុះបញ្ជីដីជាដំណើការ និងជាកិច្ចការរបស់រដ្ឋាភិបាល ម្ចាស់ដែលគ្រប់គ្រងដីអ្នកសម្រេចចិត្តក្នុងការចុះបញ្ជីដីដែលគាត់កំពង់គ្រប់គ្រង។ ករណីសម្បទានដីសេដ្ឋកិច្ច ដែលបានដកហូតពីក្រុមហ៊ុន ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន ដូចនេះក្រសួងទាំងពីរអាចចុះបញ្ជីដីដែលបានដកហូតនេះ ព្រោះរាជរដ្ឋាភិបាលបានផ្តល់សិទ្ធិប្រធានដល់ក្រសួងទាំងពីរ។ ប៉ុន្តែ ពីព្រោះតែដីទាំងនេះមិនបានចុះបញ្ជី ទើបមាន បទបញ្ជា០០១ របស់រដ្ឋាភិបាល ដូចនេះយើងត្រូវធ្វើនិយ័តកម្មឡើងវិញនូវដីទាំងនេះ។

**លោកបណ្ឌិត កែវ អូម៉ាលីស្ស៖** ជាបទពិសោធន៍ រដ្ឋបាលព្រៃឈើគ្រប់គ្រងព្រៃការពារចំនួន ១២តំបន់ យើងបានចុះបញ្ជីព្រៃការពារមួយក្នុងចំណោម ប៉ុន្តែតំបន់នោះគ្មានព្រៃ ជាក់ស្តែងមិនមានការកាប់រានដីព្រៃទេ។ យើងនឹងពិភាក្សាជាមួយក្រសួងគ្រប់គ្រងដែនដី នគររូបនីយកម្ម និងសំណង់ដើម្បីធ្វើការចុះបញ្ជីនូវតំបន់ព្រៃការពារដែលនៅសេសសល់។ ប្រសិនបើរៀបចំព្រៃការពារ រឺ អនុវត្តន៍រេដបូក យើងអាចចុះបញ្ជីជាមុនសិន ប៉ុន្តែ ករណីព្រៃឡង់វាបានចំណាយពេលជាច្រើននៅក្នុងការចុះបញ្ជី នៅក្នុងឆ្នាំ២០១០ តំបន់ព្រៃឡង់ផ្នែកខាងត្បូងមានការបាត់បង់ព្រៃឈើជាច្រើន ប្រសិនបើយើងរងចាំការចុះបញ្ជីនឹងចំណាយរយៈពេលយូរ ជាដំណោះស្រាយយើងបានស្នើសុំការអនុម័តពីអភិបាលខេត្តជាមុនសិន និងករណីនៅតំបន់ព្រៃសៀមប៉ាង នាយយករដ្ឋមន្ត្រីបានអនុម័ត ផែនទីបឋមជាមុនសិន និងចាំបាច់ធ្វើការចុះបញ្ជីជាមុនសិន។គំរូ នៃការផ្តល់សម្បទានដីផ្សេងទៀត នៅក្នុងឆ្នាំ២០១២ រដ្ឋាភិបាលបានផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ច ប៉ុន្តែនៅក្នុងតំបន់ស្រែឈូក ស្រុកកែវសីម៉ា ក្រុមហ៊ុនឯកជនបានទទួលសិទ្ធិនៅក្នុងអនុវត្តន៍សម្បទានដីសេដ្ឋកិច្ច ដោយមិនបានធ្វើEIA តើនេះជាគរូថ្មីរឺ? ជាពិសេសនោះតំបន់នោះបានជាន់តំបន់ព្រៃការពារសីម៉ា ។

**លោក សៅ រ៉ាវី៖** ការចុះ បញ្ជីមានពីរគំរូ (១)ការចុះបញ្ជីជាប្រព័ន្ធ និង(២)ការចុះបញ្ជីជាដុំ។ ជាគោលការណ៍មិនមានសម្បទានដីសេដ្ឋកិច្ចណាត្រូវបានផ្តល់ទេ ប៉ុន្តែគំរូនៃការផ្តល់សម្បទានដីផ្សេងទៀងអាចមាន។

**លោក សា ថ្លៃ៖** នៅក្នុងតំបន់សហគមន៍ ប្រសិនផ្អែកលើកិច្ចព្រមព្រៀងផ្លូវច្បាប់រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងសហគមន៍មូលដ្ឋាន។ នៅក្នុងខេត្តឧត្តរមានជ័យ ក្រុមប្រឹក្សាឃុំ បានកាត់ដីសហគមន៍ និងកាត់ដីសហគមន៍ដល់ទាហាន។ តើវាមានភាពខុសគ្នាយ៉ាងដូចម្តេចរវាង តំបន់ព្រៃសហគមន៍ និងការចុះបញ្ជីដី?

**លោក សៅ រ៉ាវី៖** ចំពោះសហគមន៍ព្រៃឈើ គឺនៅតែជាដីរបស់រដ្ឋដដែល តែគ្រាន់ តែប្រគល់សិទ្ធិដល់សហគមន៍ធ្វើការគ្រប់គ្រងដែលស្ថិតនៅដោយមានកិច្ចព្រមព្រៀងរវាងរដ្ឋ និងសហគមន៍។ ប្រសិនបើដីសហគមន៍មិនទាន់បានចុះបញ្ជីដូចដែលលោកបានលើកឡើងវាអាចឈានដល់ការបាត់បង់។

## <u>បទបង្ហាញនូវលទ្ធផលនៃក្រុមពិភាក្សាទាំងបួន៖</u>

លោក ឡុង រតនៈកុមា៖ បង្ហាញនូវលទ្ធផលក្រុមការងារចែករំលែកផលប្រយោជន៍
កញ្ញា តេង រិទ្ធីនី៖ បង្ហាញនូវលទ្ធផលក្រុមការងារប្រព័ន្ធធានាសុវត្ថិភាពរេដបូក
លោក ព្រែម សុវណ្ណា៖ បង្ហាញនូវលទ្ធផលក្រុមការងាអនុវត្តគំរូ
លោក ឡេង ជីវីន ៖បង្ហាញនូវលទ្ធផលក្រុមការងារ MRV/FREL

**<u>សំនួរ និងចម្លើយពីអ្នកចូលរួម៖</u>**

**លោក សារ ថ្លៃ៖** ប្រសិនបើរាជរដ្ឋាភិបាលបានដកដីពីក្រុមសម្បទានដីសេដ្ឋកិច្ច តែដីទាំងនោះមិនមានព្រៃទេ តើវាអាចជាដីសាធារណៈរឺទេ?

**លោក សៅ រ៉ារី៖** មិនថាដីនោះនៅព្រៃ និងគ្មានព្រៃនោះទេ គឺនៅតែជាដីឯកជនរបស់រដ្ឋដដែរ ប្រសិនបើគ្មានការធ្វើការចាត់ថ្នាក់ដីជាថ្មី។ នេះជាដំណើរសម្រេចចិត្តផ្នែករដ្ឋបាល ប្រសិនបើចង់បំលែងទីនោះជាដីសាធារណៈរបស់រដ្ឋ គឺអាស្រ័យលើការសម្រេចចិត្តរបស់ក្រសួងសាមី។

**លោកបណ្ឌិត កែវ អូម៉ាលីស្សះ** ចំពោះដី ដែលបានរឹបអូស គឺអាស្រ័យថាតើដីមានស្ថានភាពរបៀបណា ប្រសិនវានៅមានសក្តានុពលនៅក្នុងការការអភិរក្សជីវចម្រុះនោះយើងអាចរៀបចំវាទៅជាព្រៃការពារ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ មានយន្តការ និងវិធានការដាក់ពិន័យដល់ក្រុមហ៊ុនណាដែលមិនគោរពកិច្ចព្រមព្រៀង។

**<u>ថ្ងៃទី២៖ ០៧ ខែកក្កដា ឆ្នាំ២០១៦</u>**

**<u>បទបង្ហាញ ស្តីពី សេចក្តីព្រាង ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងកម្រិតបំភាយយោង (ជំពូកទី៧ - ជំពូកទី៨)នៃយុទ្ធសាស្ត្ររេដបូកជាតិ ដោយ លោក ឡេង ជីវិន៖ (សូមជូនភ្ជាប់បទបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី III)</u>**

**លោក ឡេង ជីវិន** បានបង្ហាញពី សមាសភាពសំខាន់ៗរបស់ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងកម្រិតបំភាយយោងព្រៃឈើ ដែលនឹងយកមកបញ្ចូលទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ NFMS កម្ពុជានឹងផ្តល់នូវ៖ (1) ព័ត៌មានដើម្បីត្រួតពិនិត្យ និងរាយការណ៍ស្តីពី ការអនុវត្តសកម្មភាពរេដបូក និង គាំទ្រដល់វិស័យព្រៃឈើគោលនយោបាយព្រៃឈើ និងកម្មវិធីផ្សេងទៀត ដូចជា NFP, NPASMP and SPFF។ សមាសភាពសំខាន់ៗដែលបានកំពុងប្រើប្រាស់នៅក្នុងប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិបានចែកចេញជាបីផ្នែក៖ (១) ការត្រួតពិនិត្យដីព្រៃតាមរយៈរូបភាពផ្កាយរណប, (២)សារពើភណ្ឌព្រៃឈើជាតិ និង(៣)សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់។ ប្រព័ន្ធត្រួតពិនិត្យដីតាមប្រព័ន្ធផ្កាយរណប (<u>SLMS</u>) ជាការទទួលខុសត្រូវរបស់ FA ។ ការអនុវត្ត NFI នឹងត្រូវអនុវត្តដោយ FA, FiA and MoE លើតំបន់របស់ខ្លួន។ គេហទំព័រសម្រាប់ (A Website) NFMS នឹងត្រូវរៀបចំដើម្បីចែករំលែកព័ត៌មាន ដូចជាការប្រើប្រាស់ដី/ការប្រែប្រួលគម្របដី និងស្ថិតិ ដើម្បីបំពេញជាលក្ខណៈតម្លាភាព។ ក្នុងនោះដែរ NFMS ក៏បានកំណត់និយមន័យព្រៃឈើ សម្រាប់ការអនុវត្តរេដបូក គឺ <u>*" និយមន័យព្រៃឈើ គឺត្រូវគេប្រើក្នុងការរៀបចំ NFMS គឺមានលក្ខណៈដូចគ្នានិយមន័យដែលបានប្រើនៅក្នុងនៅក្នុងកម្មវិធីព្រៃឈើជាតិបច្ចុប្បន្ន ទោះបីជាយ៉ាងណាក៏ដោយចំការកៅស៊ូត្រូវបានគេដកចេញ និងព្រៃធម្មជាតិដែលនៅសេសសល់នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចគឺត្រូវបានរាប់បញ្ចូលជាព្រៃឈើ "*</u> ។

**<u>សំនួរ និងចម្លើយរបស់អ្នកចូលរួម៖</u>**

**លោក ស៊ុំ ជាតិ៖** នៅក្នុងឆ្នាំ១៩៩៤ កម្ពុជាបានដាក់ជូនអង្គការសហប្រជាជាតិ National Communication Report ដោយផ្តោតលើឧស្ម័ន $CO_2$, CH នឹង $N_2O$ នៅក្នុងកាដាក់ NCលើកទី១(១៩៩៤) ប្រទេសកម្ពុជា $CO_2$ ជាឧស្ម័នដែល

បំភាយច្រើនជាងគេនៅក្នុងវិស័យព្រៃឈើ និងការប្រែប្រួលដី និងNC ទី២ (២០០០) ផ្តោតលើឧស្ម័ន CO2 $NH_4$ និង ប៉ុន្តែ $CO_2$ ចំនួន ៥២ , $CH_4$ ចំនួន ៤២, NH ចំនួន ៦ និងឧស្ម័នមួយចំនួនដែលមានតិចជាង ១ភាគរយ។ ខ្ញុំទទួលស្គាល់ថា $CO_2$ ឧស្ម័នដែលបានបំភាយចេញពីវិស័យព្រៃឈើ និងការប្រែប្រួលដីច្រើនជាងឧស្ម័នដទៃទៀត។

**លោក យន សារ៉េត៖** ឧស្ម័ន $CO_2$ គឺត្រូវបានជ្រើសរើស និងបង្ហាញនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ និងកម្រិតបំភាយយោងជាលើកដំបូង ប៉ុន្តែ $CH_4$ and $N_2H$, FCF នឹងត្រូវពិចារណានៅពេលដែលប្រទេសកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគណនាប្រភេទឧស្ម័នទាំងនេះ។

**លោក** Joel Scriven**៖** ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ គឺមានគោលបំណងចំនួនពីរ (១)នឹងប្រើប្រាស់សម្រាប់ធ្វើ ត្រួតពិនិត្យ រាយការណ៍ និងការផ្ទៀងផ្ទាត់ (MRV) កាបូនព្រៃឈើ និង(២)ផ្តល់ព័ត៌មានដល់ការត្រួតពិនិត្យដល់វិស័យព្រៃឈើទូលំទូលាយ។ ប៉ុន្តែ ប្រទេសកម្ពុជានៅមានចំនុចមួយចំនួនដែលមិនទាន់បញ្ជាក់ដូចជា នៅមិនទាន់កំណត់ថាក្នុងការរៀបចំស្ថាប័នក្នុងការអនុវត្តសារពើភណ្ឌព្រៃឈើជាតិ តើនរណាជាអ្នកប្រមូលព័ត៌មាន? នរណាជាអ្នករាយការណ៍ និងបញ្ជាក់? តើរៀបចំនៅក្នុងរយះពេលប៉ុន្មាន? ជាក់ស្តែងប្រទេសឥណ្ឌា រៀងរាល់១០ឆ្នាំម្តង ។ ប្រទេសកម្ពុជាកំពុងប្រើ Wall-Wall approach វាចំណាយថវិកា និងពេលវេលាច្រើន ប៉ុន្តែប្រទេស ៤១ ក្នុងចំណោម៤២ ដែលកំពុងអនុវត្តន៍រេដបូកបានប្រើប្រាស់ Sampling Approach តើប្រទេសកម្ពុជាមានផែនការនឹងប្រើប្រាស់វិធីសាស្ត្រណាទេ?

**លោក យន សារ៉េត៖** ការអនុវត្តសារពើភណ្ឌព្រៃឈើថ្នាក់ជាតិនឹងរៀបចំរៀងរាល់៥ឆ្នាំម្តង ចំពោះការធ្វើសារពើភណ្ឌជាក់ស្តែងនឹងជ្រើសរើសក្រសួងដែលពាក់ព័ន្ធនឹងអនុវត្តន៍នៅទីវាល។

**លោក** Shigeru Ono **៖** ប្រទេសកម្ពុជាបានប្រើប្រាស់ gain-loss នៅក្នុង NC1 នឹង NC2 ប្រសិនបើ ទិន្នន័យដែលកំពុងប្រើប្រាស់យើងអាចបន្តប្រើវាបាន ប៉ុន្តែប្រសិនបើចង់ប្រើ Stock-Change នោះយើងចាំបាច់ត្រូវការ ដែលនឹងទទួលបានចំនួនពីរដង។

**លោក ហុង គឹមហ៊ាន៖** នៅពេលដែលពិនិត្យមើលលើគេហទំព័រគេឃើញមានទិន្នន័យគម្របព្រៃឈើខុសៗគ្នាដែលរៀបចំដោយស្ថាប័នខុសៗគ្នា វាមានការលំបាកដល់អ្នកប្រើប្រាស់ទិន្នន័យ ដូចនេះ យើងគួរតែមានកន្លែងផ្ទុកទិន្នន័យមួយដែលអាចជឿជាក់បាន។

**លោក យៀង ដូណាល់៖** តើលោកបានប្រមូលទិន្នន័យពីអង្គការក្រៅរដ្ឋាភិបាលដែលកំពុងរៀបចំទិន្នន័យប្រមូលទិន្នន័យពីសង្គមស៊ីវិល ដូចជា Geress WCS និង WA។

**លោក យន សារ៉េត៖** ចំពោះការប្រមូលទិន្នន័យ យើងចាំបាច់ត្រូវទិន្នន័យណាដែលចាំបាច់ និងវិធីសាស្ត្រនៅក្នុងការប្រមូលទិន្នន័យ និងបញ្ជាក់ពីប្រភពទិន្នន័យផងដែរ។

**លោក** Joel Scriven៖ តាមរយៈការរៀនសូត្រពីឧបសគ្គដែលបានជួបប្រទះពីប្រទេសនានាដែលបានអនុវត្តន៍រេដបូកកន្លងមក ចំពោះ SIS, NS និង NFMS នឹងមិនមានការវាយតម្លៃជាលក្ខណៈអន្តរជាតិ ប៉ុន្តែសម្រាប់ FREL/REL នឹងមានការវាយតម្លៃជាអន្តរជាតិដោយក្រុមការងារបច្ចេកទេស ដើម្បីធានាថា FREL/REL របស់កម្ពុជាមិនមានភាពលំអៀង។ នៅពេលដែលកម្ពុជាដាក់ BUR និង NC ជូនUNFCCC នឹងមានការវាយតម្លៃជាលក្ខណៈបច្ចេកទេស ដូចនេះហើយត្រូវមាន AD NFI និង EF ការគណនាការប្រែប្រួលសន្និធិកាបូនត្រូវតែមានលក្ខណៈច្បាស់លាស់ និងតម្លាភាព។ កម្ពុជានឹងត្រូវគូសបញ្ជាក់ និងការពារនូវសំណើ FREL/REL របស់ខ្លួន។

**លោក ឡេង ជីវីន៖** ប្រទេសកម្ពុជានឹងរៀបចំកម្រិតបំភាយយោងព្រៃឈើទូទាំងប្រទេស នឹងប្រើប្រាស់សម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តសកម្មភាពរេដបូកនៅប្រទេសកម្ពុជា ។

**លោក សុខ ឡុង៖** ដោយសារឯកសាររេដបូកជាតិនេះ គឺជាឯកសារមួយសំខាន់និងមានលក្ខណៈទូលំទូលាយ នឹងត្រូវបានអនុវត្តន៍ដោយស្ថាប័នចំនួន៣ ដូចនេះនៅក្នុងជំពូកទី៩ ស្តីពីការរៀបចំស្ថាប័ននៅក្នុងការអនុវត្តរេដបូក គួរតែមានការពិភាក្សឲ្យបានពិស្តារនៅក្នុងស្ថាប័នទាំងបី។

**លោក ធឹត ឈន៖** តើដីដែលគ្រប់គ្រងដោយជនជាតិដើមភាគតិចប៉ុន្មានហើយដែលបានចុះបញ្ជី ហើយនឹងដាក់អោយនៅស្ថិតក្រោមនៃការអនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ?

**លោក ឡេង ជីវីន៖** សព្វថ្ងៃយើងមិនមានព្រំប្រទល់ដីរបស់ជនជាតិដើមភាគតិចនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យព្រៃឈើរបស់រដ្ឋបាលព្រៃឈើនៅឡើយទេ។ នាពេលចុងក្រោយនេះលោក ណុប វ៉េង បានបញ្ជាក់ថា លោកនឹងប្រមូលទិន្នទាំងនេះជូនរដ្ឋបាលព្រៃឈើតែមកដល់ពេលនេះយើងមិនទាន់មានព័ត៌មានទាំងនោះទេ។

**លោក យៀង ណូណាល់៖** ទិន្នន័យស្តីពីព្រំប្រទល់ដីជនជាតិដើមភាគតិចនៅ MLUMPC។

**លោក សៅ វារី៖** យើងបានចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចចំនួន ៨សហគមន៍រួចមកហើយ (៥សហគមន៍នៅក្នុងខេត្តមណ្ឌលគិរី និង ៣សហគមន៍នៅក្នុងខេត្តរតនៈគិរី) ហើយនឹងបន្តចុះបញ្ជីសហគមន៍ ៣ទៀតនៅក្នុងខេត្តកំពង់ស្ពឺ។ ប្រសិនបើទិន្នន័យវាមានវាមានសារៈសំខាន់ ហើយមានការស្នើសុំខ្ញុំនឹងចែករំលែកជូន។

**លោក ឡេង ជីវីន៖** រដ្ឋបាលព្រៃឈើនឹងស្នើសុំជាផ្លូវការនូវទិន្នន័យដីប្រទានកម្ម សម្បទានសង្គមកិច្ច និងដីរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងទម្រង់ជា shape file។ ប្រទេសកម្ពុជានឹងនៅបន្ត Wall to Wall ប៉ុន្តែយើងនឹងធ្វើពិចារណាទៅលើ Sampling Approach នៅពេលខាងមុខតែនៅពេលណាយើងមានធនធានមនុស្សគ្រប់គ្រាន់ និងបច្ចេកវិទ្យាគ្រប់គ្រាន់ តែ Wall to Wall ( Segmentation)នៅតែបន្តប្រើរហូត។ គូសបញ្ជាក់ថា យើងនឹងមិនបោះបង់ចោលបច្ចេកវិទ្យា Wall to Wall ទេ។

## កិច្ចពិភាក្សាជាក្រុម ស្តីពី ហានីភ័យ និងផលប្រយោជន៍ដែលអាចកើតមានចំពោះសង្គមនិងបរិស្ថានដែល អាចកើតចេញពីការអនុវត្តសកម្មភាព គោលនយោបាយ និងវិធាននៅក្នុងការដោះស្រាយបុព្វហេតុដែល បណ្តាលអោយមានការបាត់បង់ និងចុះនៃព្រៃឈើ

**ប្រធានបទ៖** ក្រុមពិភាក្សាពិគ្រោះយោបល់ និងស្វែងរកនូវ ហានីភ័យ និងផលប្រយោជន៍ដែលអាចកើតមានចំពោះសង្គមនិងបរិស្ថានដែលអាចកើតចេញពីការអនុវត្តសកម្មភាព គោលនយោបាយ និងវិធាននៅក្នុងការដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើ។ ផ្អែកលើលទ្ធផលសង្ខេប ស្តីពី បុព្វហេតុ សកម្មភាព គោលនយោបាយ និងវិធាន នៅក្នុងការដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និង ថយចុះនៃព្រៃឈើ ដែលទទួលបានពីក្រុមពិភាក្សាទាំងបួន បន្ទាប់មកក្រុមដដែលនេះនឹងពិភាក្សា និងស្វែងរកនូវ ហានីភ័យ និងផលប្រយោជន៍ដែលអាចកើតមានចំពោះសង្គមនិងបរិស្ថានដែលអាចកើតចេញពីការអនុវត្ត សកម្មភាព គោលនយោបាយ និងវិធានទាំងនេះ។

**បទបង្ហាញនូវលទ្ធផលនៃក្រុមពិភាក្សាទាំងបួន៖**

លោក អ៊ុយ ជីង៖ បង្ហាញនូវលទ្ធផលក្រុមការងារប្រព័ន្ធធានាសុវត្ថិភាពរេដបូក
លោក ហេង ហុង៖ បង្ហាញនូវលទ្ធផលក្រុមការងារចែករំលែកផលប្រយោជន៍
លោក មាស ណារូ៖ បង្ហាញនូវលទ្ធផលក្រុមការងាអនុវត្តគំរូ
លោក ហេង ហុង៖ បង្ហាញនូវលទ្ធផលក្រុមការងារចែករំលែកផលប្រយោជន៍

**សំនួរ និងចម្លើយរបស់អ្នកចូលរួម៖**

**លោក សុខ ពិសិដ្ឋ៖** សូមពន្យល់ដល់សហគមន៍ពីសារៈប្រយោជន៍ និងផលលំបាក នៃការប្រើអុស និងជីវឧស្ម័ន ដូចនេះសហគមន៍នឹងអាចពិចារណាមកប្រើឡជីវឧស្ម័ន។

**លោក ស៊ុំ សុជាតិ៖** មានចំណុចចំនួនទី២ ដែលមិនទាន់ច្បាស់នៅក្នុងសំនួរទី១៤ គឺ (១) យើងបង្កើតជម្រើសថ្មីដើម្បីកាត់បន្ថយការប្រើប្រាស់អុសធ្យូង និង ទី២ តើមានផលប៉ះពាល់អ្វីខ្លះពីការប្រើប្រាស់អុសធ្យូង តើចំណុចមួយណាសម្រាប់ការពិភាក្សានេះ?

**លោក ឈុន ឌីលុច៖** ជាចំណុចទី២។

**លោក ឡុង រតនៈកុមារ៖** ចំពោះការបោះបង្គោលព្រំ ELC ចំណុចនេះត្រូវបោះបង្គោលទាំងព្រៃសហគមន៍ និង ELC អោយច្បាស់លាស់។ ជាបទពិសោធន៍នៅពេលយើងបានបោះបង្គោលព្រំ ELC តែព្រៃសហគមន៍ដែលនៅជាប់នោះ នៅតែមិនច្បាស់ដូចនេះជំលោះព្រំប្រទល់នៅតែកើតមានដដែល។

**លោក សុខ ឡុង៖** ប្រសិនបើយើងលើកឡើងនូវហានីភ័យ ច្រើនជាងផលប្រយោជន៍ វាមានការលំបាកក្នុងការជ្រើសរើសសកម្មភាពដើម្បីអនុវត្តន៍ក្រោមយុទ្ធសាស្ត្ររេដបូកជាតិ។ ដូចបានអង្កេតលើក្រុមពិភាក្សាឃើញថាមានហានីភ័យច្រើនជាងផលប្រយោជន៍។

**លោក មាស ណារូ៖** យើងគួរតែលើកហានីភ័យអោយបានដើម្បីអោយយើងត្រៀមខ្លួនក្នុងការដោះស្រាយបញ្ហាដែលអាចកើតឡើង។ ជាទូទៅរាល់សកម្មភាពអាចមានហានីភ័យ និងផលប្រយោជន៍។

**តំណាងសហគមន៍៖** ចំពោះសារៈប្រយោជន៍នៃការប្រើចង្ក្រានហ្គាស ខ្ញុំថាវាអាចជួយសន្សំពេលវេលា តែមិនបានកាត់បន្ថការចំណាយនោះទេ។

**លោក មាស ណារូ៖** ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានដកហូត ហើយបំលែងដីទាំងនោះជាតំបន់គ្រប់គ្រងដោយសហគមន៍ ហានីភ័យនោះ គឺ សហគមន៍អាចមិនមានសមត្ថភាពគ្រប់គ្រងតំបន់នោះ ដោយសារអាចមកពីសមត្ថភាព ការចែករំលែកផលប្រយោជន៍ និង មានបទល្មើសអាចកើតមានក្នុងតំបន់សហគមន៍។

**លោក ឡាវ សេដ្ឋាផល៖** ចំពោះការប្រើឈើថាមពលសម្រាប់ក្នុងគ្រួសាររបស់សហគមន៍មូលដ្ឋានគឺមិនមានផលប៉ះពាល់ដល់ធនធានព្រៃឈើខ្លាំងទេ តែចំពោះប្រើប្រាស់ឈើថាមពលសម្រាប់ធ្វើអាជីវកម្ម និងប្រើប្រាស់ក្នុងរោងចក្រគឺជាបញ្ហា។ ភាគច្រើន ឈើ និងអុសដែលបានកំពុងប្រើនៅក្នុងរោងចក្រគឺចេញមកពីការឈូសឆាយដីសម្បទានសេដ្ឋកិច្ច។

**លោក ឡុង រតនកុមា៖** នៅក្នុងបរិបទនៃការគ្រប់គ្រងព្រៃឈើ ប្រសិនបើព្រៃឈើគ្រប់គ្រងបានល្អ តម្លៃឈើនឹងមានការកើនឡើង នេះមិនមានបណ្តាលមកពីការបង្ក្រាបបទល្មើសព្រៃឈើទេ។ ចំពោះការខ្វះខាតឈើថាមពល គឺបណ្តាលមមកពីការគ្រប់គ្រងព្រៃឈើមិនបានល្អ។

**អ្នកស្រី វង្ស សុបញ្ញា៖** នៅពេលដែលមានការពង្រឹងច្បាប់បានត្រឹមត្រូវ  នោះតម្លៃទំនិញ ដូចជា ឈើ រឺអុស នឹងមានការកើនឡើងព្រោះអ្នកដែលប្រមូលធនធានទាំងនេះត្រូវ ធ្វើការបង់ពន្ធ និងបំពេញតាមបែបបទច្បាប់នានា។ ការកាត់បន្ថយការប្រើប្រាស់ឈើថាមពល គឺកើតឡើងនៅពេលណាដែលមានការគ្រប់គ្រងព្រៃឈើបានល្អ និងតម្លៃឈើថាមពលមានការកើនឡើង ពីព្រោះតម្រូវអោយមានការបង់ពន្ធ ទាក់ទងនឹងការប្រើប្រាស់ ថាតើពួក រឺអ្នកប្រើប្រាស់ឈើថាមពល គេមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងការទិញឈើថាមពលនោះទេ។

**លោក សារ ថ្លៃ៖** ប្រសិនបើមិនមានការគ្រប់គ្រងព្រៃឈើអោយបានល្អ នោះមានឈើតិចតួចណាស់សម្រាប់ប្រើប្រាស់ ដូចនេះច្បាស់លាស់ហើយដែលតម្លៃឈើនឹងកើនឡើង។

**លោក រូ ណារិត៖** សំនួរទី៥ ការរៀបចំ PLUP គឺមិនកំណត់ថាតើដីទាំងនោះមានកម្មសិទ្ធិទាំងអស់នោះទេ គឺគ្រាន់តែកំណត់ថាតើ ដីណាសម្រាប់ធ្វើអ្វី?

**តំណាង ក្រសួងកិច្ចការនារី៖** ផែនការប្រើប្រាស់ដីដែលមានការគាំទ្រដោយ DANIDA ថាតើក្រសួងដែនដី នគររូបនីយ៍កម្ម និងសំណង់ បានចេញគោលការណ៍អោយអ្នកពាក់ព័ន្ធប្រើប្រាស់រឺនៅ? ពីព្រោះអាចប្រើប្រាស់ថវិការេដបូកមកគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

**<u>ថ្ងៃទី៣៖ ០៨ ខែកក្កដា ឆ្នាំ២០១៦</u>**

**<u>បទបង្ហាញ ស្តីពី ការស្នើឡើងនូវប្រព័ន្ធជានាសុវត្ថិភាពរេដបូក( Presentation)និងប្រព័ន្ធព័ត៌មានជានាសុវត្ថិភាពរេដបូកម្ពុជា(SIS)៖</u>**

**<u>(សូមជូនភ្ជាប់បទបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី III)</u>**

**លោក ងួន ភក្តី** បានបង្ហាញនូវចំណុចសំខាន់មួយចំនួនដែលទាក់ទងនឹងប្រព័ន្ធព័ត៌ជានាសុវត្ថិភាពរេដបូក និងប្រព័ន្ធព័ត៌មានជានាសុវត្ថិភាពរេដបូកម្ពុជា(SIS) ដែលបានស្នើឡើងនៅក្នុងសេចក្តីព្រាងទី៣ នៃយុទ្ធសាស្ត្ររេដបូកជាតិ ដូចខាងក្រោម៖

- គោលបំណងនៃប្រព័ន្ធជានាសុវត្ថិភាព
- ដំណើរការក្នុងការរៀបចំប្រព័ន្ធជានាសុវត្ថិភាពរេដបូកនៅក្នុងប្រទេសកម្ពុជា
- សេចក្តីសម្រេចរបស់ UNFCCC លើកឡើងថា រដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបង្កើតប្រព័ន្ធមួយដើម្បីផ្តល់ព័ត៌មានអំពីរបៀបដែលថា ការជានាសុវត្ថិភាពរេដបូក ត្រូវបានធ្វើឡើង និងគោរព នៅក្នុងការអនុវត្តសកម្មភាពរេដបូកទាំងមូល។
- អភិក្រម ៣ ជំហាន ដើម្បីបង្កើតប្រព័ន្ធព័ត៌មានស្តីពីការជានាសុវត្ថិភាពរបស់ខ្លួនដូចជា៖
  - ការបង្កើតសូចនាករ ផ្អែកទៅតាមសូចនាករ ដែលត្រូវបានប្រើប្រាស់ នៅក្នុងគោលនយោបាយ និងវិធានការដែលមានស្រាប់
  - ការជ្រើសរើសវិធីសាស្ត្រសម្រាប់ប្រមូល និងវិភាគទិន្នន័យ និង
  - ការកំណត់ពីការទទួលខុសត្រូវរបស់ស្ថាប័ន ក្នុងការផ្តល់ព័ត៌មាន។

**<u>សំនួរ និងចម្លើយរបស់អ្នកចូលរួម៖</u>**

**លោក យៀង ដូណាល់៖**តើប្រទេសមួយណាដែលបានដាក់ SIS ជូនអង្គការសហប្រជាជាតិ?

**លោក ធីត ឈន៖** តើប្រទេសវៀតណាម និងប្រទេសឥណ្ឌូនេស៊ី បានដាក់ជូន SIS ទៅអង្គការសហប្រជាជាតិរឺនៅ?

**លោក ងួន ភក្តី៖** មកដល់ពេលនេះមានតែប្រទេស ប្រេស៊ីល ដែលបានដាក់នូវ FREL/REL និង SIS ជូនអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាកំពុងរៀនសូត្រពីប្រទេសនេះដែរ។ ថ្ងៃទី៣នៃសិក្ខាសាលាយើងនឹងពិភាក្សាលើប្រធានបទនេះ។

**លោក សុខ ឡុង៖** នៅក្នុងដំណើការដាក់ SIS ជូនអង្គការសហប្រជាជាតិអនុវត្តន៍បានដោយរបៀបណា? យើងគួរបង្ហាញពីចំនុចណាដែលអនុវត្តជាវិជ្ជមាននៅក្នុងការអនុវត្តរេដបូក។

**លោក ងួន ភក្តី៖** សម្រាប់ប្រទេសកម្ពុជា អាចដាក់ជូននូវ SIS បានតាមរយះក្រសួងបរិស្ថានដែលជាជនបង្គោលរេដបូក ។

**លោក សុខ ពិសិដ្ឋ៖** តើដាក់ SIS អង្គការសហប្រជាជនប៉ុន្មានដង ចំពោះក្រសួងកិច្ចការនារី យើងត្រូវដាក់របាយការណ៍ CEDAW ជូនអង្គការសហប្រជាជាតិរៀងរាល់បួនឆ្នាំម្តង ដែលក្នុងនោះរដ្ឋាភិបាលជាអ្នកដាក់របាយការណ៍ និងរបាយការណ៍មួយទៀតដែលដាក់ជូនអង្គការសហប្រជាជាតិ (ដែលគេហៅថា របាយការណ៍ស្រមោល) ក្នុងគោលបំណងធ្វើផ្ទៀងផ្ទាត់ព័ត៌មានដោយអង្គការសហប្រជាជាតិ។

**លោក ងួន ភក្តី៖** ដំណើការដាក់ជូនអង្គការសហប្រជាជាតិគឺត្រូវមានភាពស៊ីគ្នាជាមួយការអនុវត្តសកម្មភាពនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។

**លោក សុខ ពិសិដ្ឋ៖** PCI on M and E ដើម្បីទទួលឥណទានកាបូនតាមយន្តការ UNFCCC ការវាយតម្លៃអាចឧបសគ្គសម្រាប់ប្រទេសកម្ពុជា។ RGC តាមរយៈ កម្មវិធីវិមជ្ឈការ និងសហវិមជ្ឈការ យើងបានទទួលបទពិសោធន៍ប្រសិនបើការកំណត់ អោយបានច្បាស់នូវសូចនាករណ៍ និងសន្ទស្ស អោយបានច្បាស់លាស់នោះវានឹងពិបាកវាស់វែងពីការអនុវត្តកម្មវិធី។ ចំពោះកម្មសកម្មភាពរេដបូកដែលមានចែងនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិគួតែមាន សូចនាករណ៍ការវាស់វែងអោយច្បាស់លាស់។ និងមានយន្តការសម្របសម្រួលរវាងស្ថាប័នដែលពាក់ព័ន្ធ។

**លោក ងួន ភក្តី៖** ប្រសិនបើយើងមានសន្ទស្សន៍មួយជាក់លាក់ ហើយយើងអាចប្រមូលបាន យើងគួរតែពិចារណាលើសមត្ថភាពក្នុងការប្រមូលទិន្នន័យ ប៉ុន្តែយើងគួរតែពិចារណាលើបទពិសោធន៍ដែលមានស្រាប់។

**លោក ស៊ុំ ជាតិ៖** នៅក្នុងប្រព័ន្ធធានាសុវត្ថិភាពរេដបូកខេឃូនទាំង ៧បានអោយអនុវត្តន៍រេដបូកដោះស្រាយបញ្ហា Permanence នឹង Reversal ប្រសិនបើយោងអនុវត្តរេដបូក តើយើងនឹងកំណត់រយៈពេលប៉ុន្មាន? ប្រទេសកម្ពុជាអាស្រ័យវិស័យកសិកម្ម ប៉ុន្តែអាចអាស្រ័យលើវិស័យឧស្សាហកម្ម ប្រហែលរេដបូកអាចបញ្ចប់រយៈពេល ១០០ឆ្នាំទៀត អាចមិនមានព្រៃឈើនៅសេសសល់ទេ។

**លោក ងួន ភក្តី៖** អន្តរជាតិមិនបានកំណត់រយៈពេលច្បាស់លាស់សម្រាប់ Permanence ប៉ុន្តែតម្រូវការអោយមានការវាយតម្លៃតាមកាលៈទេសៈរបស់ប្រទេសសម្រាប់ប្រទេសអនុវត្តរេដបូក នេះជាចំនុចគួរពិចារណានៅក្នុងការរៀបចំប្រព័ន្ធធានាសុវត្ថិភាពរេដបូក។

**កញ្ញា តេង រិទ្ធីនី៖** ចំពោះសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូក យើងគួរបង្ហាញកន្លែងដែលជាចំណុចខ្វះចន្លោះរវាងគោលនយោបាយដែលមានស្រាប់របស់រាជរដ្ឋាភិបាល និង តម្រូវការខេនយូន នៅពេលដែលយើងឃើញភាពខ្វះចន្លោះ ហើយយើងគួសបញ្ជាក់នៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកថាយើងនឹងដោះស្រាយនូវចំនុចខ្វះចន្លោះទាំងនេះ។

## <u>បទបង្ហាញ ស្តីពី ការស្នើឡើងនូវយន្តការគ្រប់គ្រប់មូលនិធិរេដបូកជាតិ និងយន្តការបំភាយថវិការរេដបូកជាតិដល់ថ្នាក់ក្រោមជាតិ៖</u>
## <u>(សូមជូនភ្ជាប់បទបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី III)</u>

**លោក ឈុន ឌីលុច** បានធ្វើបង្ហាញ ស្តីពី ការស្នើឡើងនូវយន្តការគ្រប់គ្រប់មូលនិធិរេដបូកជាតិ និងយន្តការបំភាយថវិការេដបូកជាតិដល់ថ្នាក់ក្រោមជាតិ។ ក្នុងនោះដែលលោកក៏បានបង្ហាញនូវ ការចំណាយដែលអាចកើតមានដែលគេហៅថា <u>ចំណាយប្រតិបត្តិ</u> និងចំណាយសម្រាប់អនុវត្តន៍គោលនយោបាយ និងវិធាននានា (ចំណាយសម្រាប់ការអនុវត្ត)។ ប្រភពមូលនិធិដែលអាចទទួលបានពីអន្តរជាតិ និងការប្រើប្រាស់ការទូទាត់រេដបូកផ្អែកតាមលទ្ធផលដែលបានស្នើឡើង ហើយមូលនិធិទាំងនេះអាចដាក់បញ្ចូលទៅក្នុងមូលនិធិរេដបូកជាតិ។ (មានភ្ជាប់ជូន នូវបទបង្ហាញ)

**លោក សុខ ពិសិដ្ឋ៖** រាជរដ្ឋាភិបាលមានបទពិសោធន៍នៅក្នុងការរៀបចំមូលនិធិ CCCA យើងអាចរៀនសូត្រពីបទពិសោធន៍នេះ ដើម្បីរៀបចំមូលនិធិរេដបូកជាតិ។

**លោក Joel Scriven៖** ចំពោះ GCF ត្រូវឆ្លងកាត់ដំណើការ Accreditation ចំពោះស្ថាប័នណាដែលអាចទទួលមូលនិធិដើម្បីអនុវត្តន៍។ មកដល់ពេលបច្ចុប្បន្នមានស្ថាប័នចំនួន ០៧ ប៉ុណ្ណោះដែលត្រូវបានជ្រើសរើសដោយ GCF ក្នុងនោះមាន UNDP ផងដែរ។

**លោក ងួន ភក្តី៖**ចំពោះការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ( 2016-2020)យើងនឹងរកមូលនិធិម្ចាស់ជំនួយ នឹងដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែចាប់ពីឆ្នាំ២០២០ ទៅកម្ពុជារំពឹងថានឹងទទួលបានមូលនិធិពីGCF។

**កញ្ញា តេង រិទ្ធីនី៖** ទាក់ទងនឹងការសម្រេចិត្តនៅទីក្រុងប៉ារីស ប្រសិនប្រទេសទាំងអស់មិនអាចឈានដល់កិច្ចព្រមព្រៀងទេនោះ តើរាជរដ្ឋាភិបាលនឹងអនុវត្តន៍យុទ្ធសាស្ត្ររេដបូកជាតិទេ? ចំពោះការគ្រប់គ្រងមូលនិធិរេដបូកជាតិ តើវាលំហូទៅសហគមន៍ដោយរបៀបណា? នៅក្នុងបទបង្ហាញ ខ្ញុំមិនបានឃើញ NGOs និងសហគមន៍មូលដ្ឋានចូលរួមនៅក្នុងការសម្រេច រឺនៅក្នុងគណៈកម្មការ រឺក្រុមប្រឹក្សាភិបាល។ តើវាមានតម្លាភាពទេ?

**លោក ហុង គីមហ៊ាន៖** ប្រសិនបើការវិនិយោគលើរេដបូកច្រើន ហើយផលចំណេញជាទឹកប្រាក់តិច តើនៅបន្តអនុវត្តន៍រេដបូកទេ?

**លោក ឃន សារ៉េត៖** ចំណុចទី១ ទាក់ទងការងារបច្ចេកទេស យើងកំពុងរៀបចំឯកសារមួយដើម្បីវាស់ពីលទ្ធផលដែលកំពុងអនុវត្តក្នុងការដោះស្រាយការបាត់បង់ និងការថយចុះនៃព្រៃឈើ។ MRV កំពុងរៀបចំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ចំណុចទី២ ការងារគ្រប់គ្រងមូលនិធិ យើងត្រូវដឹងថាតើត្រូវកាថវិកាចំនួនប៉ុន្មានក្នុងការអនុវត្តសកម្មភាព? នៅពេលខាងមុខចំពោះការគ្រប់មូលនិធិរេដបូកនេះនឹងមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លោក ងួន ភក្តី៖** យើងមិនទាន់ដឹងថាតើប្រទេសដែលនឹងចូលរួមប្រជុំ COP សម្រេចដោយរបៀបណា? ប៉ុន្តែកស្តុតាងមួយចំនួនបានបង្ហាញថាមានការព្រមព្រៀងកើតឡើងរួចមកហើយ រាល់ការសម្រេចចិត្តបានសម្រេចចិត្ត រៀងរាល់ COP។

**លោក ឈុន ឌីលុច៖** ទាក់ទងការស្នើឡើងនូវ Diagram។ នៅក្នុងក្រុមប្រឹក្សាភិបាលមិនតំណាងរាជរដ្ឋាភិបាលនោះទេ ថែមទាំងមានតំណាងអ្នកពាក់ព័ន្ធនានា។ ម្ចាស់ជំនួយមានគោលបំណងផ្សេងៗគ្នា ពួកគេប្រហែលអាចអោយតំណាង NGOs និងសហគមន៍មូលដ្ឋានចូលរួមនៅក្នុងក្រុមប្រឹក្សាភិបាលនោះដែរ អាស្រ័យលើប្រភពថវិកាមកពីណា និងម្ចាស់ជំនួយប្រភេទណា។

**លោក ងួន ភក្តី៖** ចំណុចដែលសំខាន់នោះយើងមិនដឹងថវិកាបានមកពីប្រភពណាសម្រាប់ការអនុវត្តសកម្មភាពឆ្នាំ ២០១៦-២០២០ ប៉ុន្តែក៏អាស្រ័យលើច្បាប់ និងបទបញ្ញត្តិដែលមានស្រាប់របស់ប្រទេសយើងដែរ។ នៅក្នុងដំណាក់កាលរៀបចំខ្លួនយើងបានប្រើមូលនិធិរបស់ UN-REDD និង FCPF ដែលគ្រាំទ្រដល់ប្រទេសក្នុងការរៀបចំសិក្ខាសាលា សិក្សាពី Cost and Benefits ក្នុងការអនុវត្តរេដបូកនៅក្នុងប្រទេសកម្ពុជា។

**លោក Bruno៖** មិនត្រឹមតែ UNFCCC ដែលផ្តល់ការទូទាត់សង មានមូលនិធិទ្វេភាគី ដូចជា Brazil និងNorway។ ចំពោះមូលនិធិក្នុងការអនុវត្តយុទ្ធសាស្ត្រវិញប្រទេស Mexico បានវិនិយោគថវិកាជាតិចំនួន ៤៣ភាគរយ ក្នុងការអនុវត្តយន្តការរេដបូក ពីព្រោះគេគិតថាវាជា គោលបំណងរបស់ផែនការអភិវឌ្ឍជាតិមួយដែរ។ ចំពោះវិស័យឯកជន និងជំនួយក្រៅប្រទេស ក៏មានសារៈសំខាន់ដែរក្នុងចូលរួមថវិកាអនុវត្តន៍សកម្មភាពរេដបូក។

## បទបង្ហាញ ស្តីពី ផែនការពិគ្រោះយោបល់យុទ្ធសាស្រ្តរេដបូកទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ

| សកម្មភាព | កាលបរិច្ឆេទ |
|---|---|
| គ្រោងឆ្អឹងនៃយុទ្ធសាស្ត្រ | ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៤ |
| សេចក្តីព្រាងដំបូង | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ |
| សេចក្តីព្រាងលើកទីពីរ/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ |

| | |
|---|---|
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ជាមួយ TF, TTs, CG, GG | ថ្ងៃទី ២០-២១ ខែឧសភា ឆ្នាំ២០១៥ |
| សេចក្តីព្រាងលើកទី ៣/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី ២ ជាមួយ TF, TTs, CG, GG | ថ្ងៃទី ៦-៨ ខែ កក្កដា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី៤/ឯកសារសាវតារ | ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិចំនួនបួនលើក៖<br>• ខេត្តក្រចេះ<br>• ខេត្តព្រះសីហនុ<br>• ខេត្តបាត់ដំបង<br>• ខេត្តសៀមរាប<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល នៅថ្នាក់ខេត្ត សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច) | ថ្ងៃទី ០៨-០៩ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ១៥-១៦ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២២-២៣ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ/ ភ្នំពេញ<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ TF, TTs, CG និង GG) | សប្តាហ៍ទីបី ខែតុលា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី ៥/ចុងក្រោយ/ ឯកសារសាវតារ | ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ |
| ការអនុម័តគាំទ្រដោយ MAFF/ MoE/ PM | នៅមុន COP 21, ទីក្រុងប៉ារីស |
| ការធ្វើបទបង្ហាញ/ការផ្សព្វផ្សាយយុទ្ធសាស្រ្តរេដបូកជាតិនៅក្នុង COP21 | ថ្ងៃទី ៣០ វិច្ឆិកា ដល់ ១១ ធ្នូ ២០១៥ |

សំគាល់៖ TF: ក្រុមការងាររេដបូក, TTs: ក្រុមបច្ចេកទេស, CG: ក្រុមពិគ្រោះយោបល់, GG: ក្រុមយេនឌ័រ

(ឧបសម្ព័ន្ធ ।)

**ប្រធានបទ:** ក្រុមពិភាក្សា ស្តីពី ការពិគ្រោះយោបល់ និងកែសម្រួលលើ បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើ និង សម្មភាព/ផែនគោលនយោបាយ និងវិធានដើម្បីដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើ

## លទ្ធផលក្រុមការបច្ចេកទេសចែករំលែកផលប្រយោជន៍៖

| បុព្វហេតុ | | សំណើសកម្មភាព |
|---|---|---|
| ផ្ទាល់ ( Direct ) | សម្បទានដី | **១.ច្បាប់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច**<br>តាំងពីឆ្នាំ២០១២មក រាជរដ្ឋាភិបាលបានផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន បាននិងកំពុងត្រួតពិនិត្យផ្ទៀងផ្ទាត់ទៅលើស្ថានភាពរបស់សម្បទានដីសេដ្ឋកិច្ច នឹងបានដកហូត សម្បទានដីសេដ្ឋកិច្ចមួយចំនួន ដោយសារការមិនគោរពច្បាប់សម្បទានដីសេដ្ឋកិច្ច។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំលុបចោលសម្បទានដីសេដ្ឋកិច្ចចំនួន ៤១កន្លែង ដែលផ្ទៃដីសរុបចំនួន ៣៧៩.០០០ ហិកតា ខណៈដែលក្រសួង បរិស្ថានបានលុបចោលដូចគ្នាចំនួន ២៣ កន្លែង ដែលមានទំហំដីប្រមាណជាង ៩០០០០ ហិកតា។ ផ្អែកលើការសម្រេចចិត្ត របស់រាជរដ្ឋាភិបាល ហិរញ្ញវត្ថុបានទទួលពីយុទ្ធសាស្ត្ររេដបូកជាតិ អាចត្រូវបានប្រើប្រាស់ ដើម្បីជួយរដ្ឋាភិបាល ដូចខាងក្រោម:<br>1. ពន្យារពេលនៃ~~ការផ្អាក~~ការផ្តល់សម្បទានដីសេដ្ឋកិច្ចយ៉ាងតិច XXX ឆ្នាំ ៖<br>• សិក្សាផលប៉ះពាល់ដល់សង្គម និងបរិស្ថានក្នុងការអភិវឌ្ឍន៍ ELC<br>• សិក្សាពីតម្លៃជីវៈចម្រុះ និងELC<br>2. បន្តការស៊ើបអង្កេតពីស្ថានភាពរបស់សម្បទានដីសេដ្ឋកិច្ច<br>~~3. ត្រួតពិនិត្យនីតិវិធីនៃការផ្តល់ដីសម្បទានសង្គមកិច្ចដែលប៉ះពាល់ដល់ការបាត់បង់ និងរេចរឹលព្រៃឈើ~~<br>4. ~~ពង្រឹងទម្រង់ការត្រួតពិនិត្យ វាយតម្លៃ និងដំណើរការផ្លូវច្បាប់ និងគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដើម្បីសម្រេចបានទស្សនៈវិស័យរបស់រដ្ឋាភិបាលដែលថា~~ សម្បទានដីសេដ្ឋកិច្ចជាយន្តការដើម្បីធ្វើឲ្យប្រសើរឡើងនូវកំណែទម្រង់ដីធ្លី និងការអភិវឌ្ឍន៍ជនបទ។<br>5. (2+4)ពង្រឹងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តសម្បទានដីសេដ្ឋកិច្ច<br>• ពង្រឹងយន្តការ ការវាយតម្លៃផលប៉ះពាល់ដល់បរិស្ថាន ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ<br>• បន្តការតាមដានវាយតម្លៃការអនុវត្ត ELC<br>**២.ច្បាប់ និងការគ្រប់គ្រងនៃសម្បទានដីសង្គមកិច្ច**<br>ដូចដែលបានបញ្ជាក់ក្នុងអនុក្រឹត្យលេខ១៩ សម្បទានដីសង្គមកិច្ចត្រូវបានផ្តល់សម្រាប់ការអភិវឌ្ឍន៍សហគមន៍ជនបទ ប្រើប្រាស់ជាលក្ខណៈផលិតកម្មកសិកម្មខ្នាតតូច និងការពង្រីកភូ |

| | | |
|---|---|---|
| | | មិ។ការកាប់សម្អាតដើមឈើនៅលើដីសម្បទានសង្គមកិច្ចត្រូវបានប្រើប្រាស់នៅក្នុងសហគមន៍ និង មិនសម្រាប់ធ្វើពាណិជ្ជកម្ម។ការសិក្សាកន្លងមកបានរកឃើញថា សម្បទានដីសង្គមកិច្ចដែលបានផ្តល់ជូនក្រុមគ្រួសារកងទ័ព ជនអន្តោប្រវេសន៍ គ្រួសារគ្មានផ្ទះសម្បែង និងសកម្មភាពកាប់រានផ្សេងទៀតមានការជាប់ពាក់ពន្ធ័យ៉ាងសំខាន់នឹងការបាត់បង់ព្រៃឈើ។ ដូច្នេះយុទ្ធសាស្រ្តរេដបូកជាតិ គួរផ្តោតលើសកម្មភាពមួយចំនួនដូចជាៈ<br>1. បង្កើនប្រសិទ្ធភាពការអនុវត្ត ~~និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩~~<br>~~2. ពង្រឹងការសម្របសម្រួលការប្រើប្រាស់ដីដែលបានផ្តល់ជាសម្បទានដីសង្គមកិច្ច~~<br>3. ត្រួតពិនិត្យនីតិវិធីនៃការផ្តល់ដីសម្បទានសង្គមកិច្ចដែលមានតទ្ធិពលទៅលើការបាត់បង់ និងរេចរឹលព្រៃឈើ<br>4. គ្រប់គ្រងស្ថានភាពការតាំងទីលំនៅស្របច្បាប់នៅក្នុងតំបន់ព្រៃ និងទប់ស្កាត់ការតាំងទីលំនៅថ្មី<br>5. ផ្តល់ការងារ និងមុខរបរផ្សេងៗ សម្រាប់ប្រជាពលរដ្ឋសហគមន៍ ~~អន្តោប្រវេសន៍~~ ជនចំណូលស្រុក និងគ្រួសារកងទ័ព។<br>**៣.ការធ្វើឲ្យប្រសើរឡើងនូវកាបូនស្តុកព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព**<br>ចំពោះសម្បទានដីសេដ្ឋកិច្ចដែលមិនមានសកម្មភាព ឬដីសម្បទានសង្គមកិច្ចមិនដំណើរការ ហិរញ្ញវត្ថុបានទទួលសម្រាប់យុទ្ធសាស្រ្តរេដបូកថ្នាក់ជាតិ អាចជួយរាជរដ្ឋាភិបាល ជាពិសេសសជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានដើម្បីៈ<br>1. ស្តារព្រៃនៅតំបន់ដីរេចរឹល<br>ជំរុញការធ្វើអនុបយោគ ELC ដែលបានដកហូតមកជាដីសាធារណៈរបស់រដ្ឋ (ដីព្រៃឈើ)<br>2. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ រឺសហគមន៍នេសាទ<br>3. ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ<br>4. បន្តអភិវឌ្ឍន៍កសិកម្មនៅតំបន់រេចរឹលដែលដកហូតពីដីសម្បទានសេដ្ឋកិច្ចដែលមានកាបូនតិចនិងប្រយោជន៍រួម |
| | ពង្រឹងការអនុវត្តច្បាប់ កាប់ឈើខុសច្បាប់ ការកាប់រានទន្រ្ទានយកដីជាកម្មសិទ្ធ | យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣(២០១៣-២០១៨) បានបញ្ជាក់យ៉ាងជាក់លាក់អំពីការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ ដែលជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពនៅកម្ពុជា។ យុទ្ធសាស្រ្តចតុកោណនេះ រួមមានពង្រឹងការអនុវត្តច្បាប់ នីតិវិធីប្រឆាំងនឹងបទល្មើស និងជនទាំងឡាយណាដែលកាប់ឈើខុសច្បាប់ និងការកាប់រានទន្រ្ទានយកដីជាកម្មសិទ្ធ។ នីតិវិធីទាំងនោះស្ថិតនៅក្រោម កម្មវិធីព្រៃឈើជាតិ NPASMP and SPFF។ យុទ្ធសាស្រ្តរេដបូកជាតិ នឹងចូលរួមចំណែកទៅលើការខិតខំប្រឹងប្រែងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោមៈ |

| | | |
|---|---|---|
| | | 1. បង្កើនសមត្ថភាព~~ផ្នែក~~ និងប្រសិទ្ធភាព (ហិរញ្ញវត្ថុ បច្ចេកទេស នយោបាយ និងរដ្ឋបាល) នៃស្ថាប័នអនុវត្តន៍ច្បាប់ព្រៃឈើ<br>និងស្ថាប័នផ្សេងៗទៀត ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ<br>2. ផ្សព្វផ្សាយអំពីសិទ្ធិ និងការទទួលខុសត្រូវទាក់ទងដី និងការគ្រប់គ្រងព្រៃឈើ<br>~~3. គាំទ្រការអភិវឌ្ឍនៅនឹងកន្លែង កន្លែងដែលអន្តោប្រវេសន៍ ជនចំណូលស្រុក ចូលទៅរស់នៅតំបន់ព្រៃ~~<br>4. ធ្វើឲ្យប្រសើរឡើងនូវការទទួលបានព័ត៌មានជាសាធារណៈ និងការផ្សព្វផ្សាយទាក់ទងច្បាប់ព្រៃឈើ និងច្បាប់ពាក់ព័ន្ធ<br>~~5. បណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាអំពីច្បាប់ព្រៃឈើ តួនាទីភារកិច្ច ដែលមានបញ្ជាក់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៧~~<br>ពង្រឹង និងបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងស្ថាប័នពាក់ព័ន្ធ<br>6. ជម្រុញការចូលរួមពីអ្នកពាក់ពន្ធ័ ជាពិសេសអ្នកពាក់ពន្ធ័នៅមូលដ្ឋាន ក្នុងការរៀបចំប្រព័ន្ធបង្ក្រាប និងបង្ការឧក្រិដ្ឋកម្មព្រៃឈើ<br>7. បង្កើតយន្តការឆ្លើយតបឧក្រិដ្ឋកម្មព្រៃឈើ និងបទល្មើសកាប់បំផ្លាញព្រៃលិចទឹក នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីត្រួតពិនិត្យ បញ្ជាក់ និងដោះស្រាយរបាយការណ៍សកម្មភាពបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃយកជាកម្មសិទ្ធិ |
| | កម្មវិធីទ្រទ្រង់ជីវភាពឲ្យមាននិរន្តរភាព សកម្មភាពប្រមូលអុស សកម្មភាពប្រើប្រាស់ដីខ្នាតតូចដែលគ្មាននិរន្តរភាព | យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣(២០១៣-២០១៨) បានបញ្ជាក់ច្បាស់អំពីសិទ្ធនៃការកាន់កាប់ដី ដែលជាយន្តការមួយដើម្បីសម្រេចបានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព។ កម្មវិធីព្រៃឈើជាតិបង្ហាញថាការកំណត់ព្រំតំបន់ព្រៃឈើ និងការពង្រីកតំបន់ជាសហគមន៍ព្រៃឈើជាសកម្មភាពចម្បង។ សកម្មភាពការខិតខំប្រឹងប្រែងដើម្បីផ្តល់បណ្ណ័កម្មសិទ្ធិដីធ្លីសម្រាប់ជនជាតិដើមភាគតិចមានភាពយឺតយ៉ាវ។ ការសិក្សាបានបង្ហាញថាការប្រមូលអុសមិនមាននិរន្តភាព និងសកម្មភាពប្រើប្រាស់ដីទំហំតូច មិនមាននិរន្តភាព គឺជាកត្តាចម្បងដែលនាំឲ្យបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា។ ដូចនេះ យុទ្ធសាស្រ្តរេដបូកថជាតិអាចចូលរួមចំណែកដូចខាងក្រោមៈ<br>1. ការធ្វើឲ្យបានច្បាស់នូវសិទ្ធប្រើប្រាស់ដីធ្លី តាមរយៈការអភិវឌ្ឍនិងការរក្សាកិច្ចព្រមព្រៀងប្រើប្រាស់ដីធ្លីជាមួយសហគមន៍មូលដ្ឋាន<br>2. ជួយបង្កើនល្បឿនដល់ការផ្តួចផ្តើមដែលកំពុងអនុវត្តន៍ដោយរាជរដ្ឋាភិបាល ក្នុងការទទួលស្គាល់សិទ្ធិរបស់សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ តាមរយៈការធ្វើឲ្យមានភាពសមញ្ញនូវដំណើរការអនុម័តដ៏ស្មុគស្មាញ និងវែងអន្លាយនាពេលបច្ចុប្បន្ន ។<br>3. នៅទីកន្លែងដែលឥន្ធនៈមានប្រភពពីឈើ(អុស) មិនអាចអភិវឌ្ឍន៍ ឬ មិនអាចផ្គត់ផ្គង់ប្រកបដោយនិរន្តភាព ត្រូវណែនាំជម្រើសនានា ដែលអាចបន្ថយនូវការប្រើប្រាស់ថាមពលដែលមានប្រភពពីកាបូន។<br>4. ផ្តល់សកម្មភាពមុខរបរទ្រទ្រង់ជីវភាពរស់នៅដែលអាចកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ មានដូចជា៖ |

| | | |
|---|---|---|
| | | - ផ្តល់នូវសកម្មភាពផ្សព្វផ្សាយកសិកម្ម<br>- បង្កើតគម្រោងទ្រទ្រង់ជីវភាពរស់នៅដោយផ្អែកលើអនុផលព្រៃឈើ<br>- បង្កើតសកម្មភាពដែលអាចរកចំណូលដល់សហគមន៍មូលដ្ឋានដូចជាអេកូទេសចរណ៍ |
| | ភ្លើងព្រៃ | ការសិក្សាបានបង្ហាញថាផលប៉ះពាល់ចម្បងនៃភ្លើងព្រៃនៅប្រទេសកម្ពុជា បានបំផ្លាញនូវប្រភេទព្រៃស្រោង ដែលងាយរងគ្រោះដោយសារភ្លើង ដែលធ្វើឲ្យផ្ទៃដីព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងដ៏ធំធេង ប្រែក្លាយទៅជាតំបន់ព្រៃល្បោះ។ ដំណើរការនេះ កំពុងវិវត្តន៍ទៅមុខនៅក្នុងប្រទេសកម្ពុជា និងធ្វើឲ្យផ្ទៃដីព្រៃពាក់កណ្តាលស្រោងភាគច្រើនបំផុត បានប្រែក្លាយទៅជាតំបន់ព្រៃល្បោះ ធ្វើឲ្យបាត់បង់គុណភាពដី និងប្រែក្លាយដីទៅជាស្រទាប់រឹងដែលកាត់បន្ថយដីជាតិដី ជីវម៉ាស់ និងកាបូនស្តុកទាំងខាងលើ និងខាងក្រោមដី។ បច្ចុប្បន្ន បទបញ្ញត្តិ ដែលទាក់ទង នឹងភ្លើងព្រៃនៅប្រទេសកម្ពុជា មានគោលបំណងការពារកុំឲ្យភ្លើងឆេះព្រៃឈើ ទោះបីជានៅក្នុងច្បាប់ព្រៃឈើមានការអនុញ្ញាតឲ្យប្រើភ្លើងសម្រាប់ការថែទាំព្រៃឈើក៏ដោយ។ ជាមួយនិងការអភិវឌ្ឍយុទ្ធសាស្ត្ររេដបូកជាតិ នឹងឈរលើទស្សនៈផ្សេងៗស្តីពីតួនាទីរបស់ភ្លើងព្រៃក្នុងការថែរក្សាកាបូនព្រៃឈើ ដែលទាមទារឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីធ្វើឲ្យគោលនយោបាយកាន់តែមានភាពសមស្រប។ នៅក្នុងពេលជាមួយគ្នានេះ យុទ្ធសាស្ត្ររេដបូកជាតិគួរផ្តោតទៅលើ៖<br>1. វិធានការណ៍ការពារភ្លើងឆេះព្រៃរួមមានការជម្រះយកចេញនូវឈើងាប់មួយចំនួន និងការកសាងផ្លូវភ្លើងសម្រាប់ការពារ ការរីករាលដាលនៃការដុតភ្លើង និងការឆេះព្រៃបណ្តាលមកពីកត្តាធម្មជាតិ<br>2. សិក្សាស្រាវជ្រាវបន្ថែមទៅលើឥទ្ធិពលនៃភ្លើងឆេះព្រៃដែលបណ្តាលមកពីកត្តាធម្មជាតិ និងមនុស្ស និងភាពញឹកញាប់នៃការ កើតឡើងភ្លើងព្រៃទៅលើដង់ស៊ីតេកាបូនព្រៃឈើ។ |
| | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | តាមការពិនិត្យមើលទៅលើស្ថានភាពបច្ចុប្បន្ននៃផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច និងដើម្បីបំពេញតម្រូវការថាមពលស្របតាមការរីកចំរើនផ្នែកសេដ្ឋកិច្ច។ ជាងនេះទៅទៀត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០១៣-២០១៨) បានបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដោយធានាបាននិរន្តភាពបរិស្ថាន។ ដោយសារមូលហេតុនេះ យុទ្ធសាស្ត្ររេដបូកជាតិ គួររួមចំណែកបំពេញការងារដូចខាងក្រោម៖<br>1. ផ្តល់ការគាំទ្រ (បច្ចេកទេស ហិរញ្ញវត្ថុ ច្បាប់) ដើម្បីពង្រឹងក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា អនុវត្តន៍ឲ្យមាន ប្រសិទ្ធភាពនូវច្បាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន(EIA)<br>2. ផ្តល់ការគាំទ្រ (បច្ចេកទេស ហិរញ្ញវត្ថុ ច្បាប់) ដើម្បីពង្រឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការអនុវត្តជំពូក ដែលមាននៅក្នុងច្បាប់ព្រៃឈើឆ្នាំ២០០២ ស្តីពីប្រតិបត្តិការរុករករ៉ែក្នុងតំបន់ព្រៃអចិន្ត្រៃយ៍របស់រដ្ឋ |

| | | |
|---|---|---|
| | | 3. គាំទ្រឲ្យមានតម្លាភាព គណនេយ្យភាព និងធ្វើការពិគ្រោះយោបល់ឲ្យបានពេញលេញ និងមានប្រសិទ្ធភាព និងការចូលរួមពីអ្នកពាក់ព័ន្ធទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់ព្រៃឈើ<br>4. លើកកម្ពស់ការទទួលបានព័ត៌មានជាសាធារណៈ និងការប្រកាសនានាដែលទាក់ទងនិងផែនការ អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) |

## លទ្ធផលក្រុមបច្ចេកទេសអនុវត្តរេដបូកគម្រូ៖

| បុព្វហេតុ ( Drivers ) | | សំណើសកម្មភាព ( Proposed Activities ) |
|---|---|---|
| ដោយផ្ទាល់ ( Direct ) | Concessions<br>សម្បទានដី | **១.ច្បាប់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច**<br>តាំងពីឆ្នាំ២០១២មក រាជរដ្ឋាភិបាលបានផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុន។ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន បាននិងកំពុងត្រួតពិនិត្យផ្ទៀងផ្ទាត់ទៅលើស្ថានភាពរបស់សម្បទានដីសេដ្ឋកិច្ច នឹងបានដកហូតសម្បទានដីសេដ្ឋកិច្ចមួយចំនួនដោយសារការមិនគោរពច្បាប់សម្បទានដីសេដ្ឋកិច្ច។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំលុបចោលសម្បទានដីសេដ្ឋកិច្ចចំនួន ៤១កន្លែង ដែលផ្ទៃដីសរុបចំនួន ៣៧៩.000 ហិកតា ខណៈដែលក្រសួងបរិស្ថានបានលុបចោលដូចគ្នាចំនួន ២៣ កន្លែង ដែលមានទំហំដីប្រមាណជាង ៩0000 ហិកតា។ ផ្អែកលើការសម្រេចចិត្ត របស់រាជរដ្ឋាភិបាល ហិរញ្ញវត្ថុបានទទួលពីយុទ្ធសាស្ត្ររេដបូក ជាតិ អាចត្រូវបានប្រើប្រាស់ ដើម្បីជួយរដ្ឋាភិបាលដូចខាងក្រោមៈ<br>6. ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្ត្រប្រើប្រាស់ដីច្បាស់លាស់<br>7. បន្តការ ត្រួតពិនិត្យ ពីស្ថានភាព និងវឌ្ឍនៈភាពរបស់សម្បទានដីសេដ្ឋកិច្ច<br>8. ត្រួតពិនិត្យនីតិវិធីនៃការផ្តល់ដីសម្បទានសង្គមកិច្ច ដែលប៉ះពាល់ដល់ការបាត់បង់ និងរេចរឹលព្រៃឈើ និងការពិគ្រោះយោបល់ជាមុនជាមួយសហគមន៍<br>9. ពង្រឹងទម្រង់ការត្រួតពិនិត្យ វាយតម្លៃ និងដំណើរការផ្លូវច្បាប់ និងគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដើម្បីសម្រេចបានទស្សនៈវិស័យរបស់រដ្ឋាភិបាលដែលធានាថា ការផ្តល់សម្បទានដីសេដ្ឋកិច្ចជាយន្តការដើម្បីធ្វើឲ្យប្រសើរឡើងនូវកំណែទម្រង់ដីធ្លី និងការអភិវឌ្ឍន៍ជនបទ។<br>10. កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានអោយបានច្បាស់លាស់នៅទីវាល<br>**២.ច្បាប់ និងការគ្រប់គ្រងនៃសម្បទានដីសង្គមកិច្ច**<br>ដូចដែលបានបញ្ជាក់ក្នុងអនុក្រឹត្យលេខ១៩ សម្បទានដីសង្គមកិច្ចត្រូវបានផ្តល់សម្រាប់ការអភិវឌ្ឍន៍សហគមន៍ជនបទ ប្រើប្រាស់ជាលក្ខណៈផលិតកម្មកសិកម្មខ្នាតតូច និងការពង្រីកភូមិ។ ការកាប់សម្អាតដើមឈើនៅលើដីសម្បទានសង្គមកិច្ចត្រូវបានប្រើប្រាស់នៅក្នុងសហគមន៍ និងមិនសម្រាប់ធ្វើពាណិជ្ជកម្ម។ ការសិក្សាកន្លងមកបានរកឃើញថា សម្បទានដីសង្គមកិច្ចដែលបានផ្តល់ជូន |

| | | |
|---|---|---|
| | | ក្រុមគ្រួសារកងទ័ព ជនអន្តោប្រវេសន៍ គ្រួសារគ្មានផ្ទះសម្បែង និងសកម្មភាពកាប់រានផ្សេងទៀត មានការជាប់ពាក់ពន្ធ័យ៉ាងសំខាន់នឹងការបាត់បង់ព្រៃឈើ។ ដូច្នេះយុទ្ធសាស្ត្ររេដបូក ជាតិ គួរផ្តោតលើសកម្មភាពមួយចំនួនដូចជាៈ<br>6. បង្កើនប្រសិទ្ធភាពការអនុវត្ត និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩<br>7. រៀបចំ និងពង្រឹងការសម្របសម្រួលការរៀបចំផែនការប្រើប្រាស់ដីដែលបានផ្តល់ជាសម្បទានដីសង្គមកិច្ច<br>8. ត្រួតពិនិត្យនីតិវិធីនៃការផ្តល់ដីសម្បទានសង្គមកិច្ច ដែលមានតទ្ធិពលទៅលើការបាត់បង់ និងរេចរឹលព្រៃឈើ<br>9. គ្រប់គ្រងការតាំងទីលំនៅមិនស្របច្បាប់នៅក្នុងតំបន់ព្រៃ<br>10. ផ្តល់ការងារ និងមុខរបរផ្សេងៗ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់សម្បទានសង្គមកិច្ច។<br>**៣.ការធ្វើឲ្យប្រសើរឡើងនូវកាបូនស្តុកព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព**<br>ចំពោះសម្បទានដីសេដ្ឋកិច្ចដែលមិនមានសកម្មភាព ឬដីសម្បទានសង្គមកិច្ចមិនដំណើរការ ហិរញ្ញវត្ថុបានទទួលសម្រាប់យុទ្ធសាស្ត្ររេដបូកថ្នាក់ជាតិ អាចជួយរាជរដ្ឋាភិបាល ជាពិសេសសជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានដើម្បីៈ<br>5. ស្តារព្រៃនៅតំបន់ដីរេចរឹល<br>6. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍នេសាទ គម្រូគ្រប់គ្រងព្រៃឈើផ្សេងៗទៀត<br>7. ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>8. បន្តអភិវឌ្ឍន៍កសិកម្មនៅតំបន់រេចរឹលដែលដកហូតពីដីសម្បទានសេដ្ឋកិច្ចដែលមានកាបូនតិចនិងប្រយោជន៍សាធារណៈ |
| | ពង្រឹងការអនុវត្តច្បាប់ កាប់ឈើខុសច្បាប់ ការកាប់រានទន្ទ្រានយកដីជាកម្មសិទ្ធិ | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣(២០១៣-២០១៨) បានបញ្ជាក់យ៉ាងជាក់លាក់អំពីការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ ដែលជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពនៅកម្ពុជា។ យុទ្ធសាស្ត្រចតុកោណនេះរួមមានពង្រឹងការអនុវត្តច្បាប់ នីតិវិធីប្រឆាំងនឹងបទល្មើស និងជនទាំងឡាយណាដែលកាប់ឈើខុសច្បាប់ និងការកាប់រានទន្ទ្រានយកដីជាកម្មសិទ្ធ។ នីតិវិធីទាំងនោះស្ថិតនៅក្រោម កម្មវិធីព្រៃឈើជាតិ NPASMP and SPFF។ យុទ្ធសាស្ត្ររេដបូកជាតិ នឹងចូលរួមចំណែកទៅលើការខិតខំប្រឹងប្រែងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោមៈ<br>8. បង្កើនសមត្ថភាពផ្នែក (ហិរញ្ញវត្ថុ បច្ចេកទេស នយោបាយ និងរដ្ឋបាល) នៃស្ថាប័នអនុវត្តន៍ច្បាប់ព្រៃឈើ ច្បាប់តំបន់ការពារធម្មជាតិ ផែនការយុទ្ធសាស្ត្រជលផលច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។ |

| | | |
|---|---|---|
| | | និងស្ថាប័នផ្សេងៗទៀត ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ<br>9. ផ្សព្វផ្សាយអំពីសិទ្ធិ និងការទទួលខុសត្រូវទាក់ទងដី និងការគ្រប់គ្រងព្រៃឈើដល់អ្នកពាក់ព័ន្ធ<br>10. ធ្វើឲ្យប្រសើរឡើងនូវការទទួលបានព័ត៌មានជាសាធារណៈដល់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយទាក់ទងច្បាប់ព្រៃឈើ ច្បាប់តំបន់ការពារធម្មជាតិ ផែនការយុទ្ធសាស្ត្រជលផល ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។<br>11. បណ្តុះបណ្តាលអ្នកពាក់ព័ន្ធស្តីពីតួនាទីភារកិច្ច ដែលមានបញ្ជាក់ក្នុងក្រមព្រហ្មទណ្ឌថ្មី<br>12. ជម្រុញការចូលរួមពីអ្នកពាក់ពន្ធ័ ជាពិសេសអ្នកពាក់ពន្ធ័នៅមូលដ្ឋាន ក្នុងការរៀបចំប្រព័ន្ធបង្ក្រាប និងបង្ការឧក្រិដ្ឋកម្មព្រៃឈើ<br>13. បង្កើតយន្តការឆ្លើយតបឧក្រិដ្ឋកម្មព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីត្រួតពិនិត្យ បញ្ជាក់ និងដោះស្រាយរបាយការណ៍សកម្មភាពបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃយកជាកម្មសិទ្ធិ |
| | កម្មវិធីទ្រទ្រង់ជីវភាពឲ្យមាននិរន្តរភាព សកម្មភាពប្រមូលអុស សកម្មភាពប្រើប្រាស់ដីខ្នាតតូចដែលគ្មាននិរន្តរភាព | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣(២០១៣-២០១៨) បានបញ្ជាក់ច្បាស់អំពីសិទ្ធនៃការកាន់កាប់ដី ដែលជាយន្តការមួយដើម្បីសម្រេចបានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព។ កម្មវិធីព្រៃឈើជាតិបង្ហាញថាការកំណត់ព្រំតំបន់ព្រៃឈើ និងការពង្រីកតំបន់ជាសហគមន៍ ព្រៃឈើជាសកម្មភាពចម្បង។ សកម្មភាពការខិតខំប្រឹងប្រែងដើម្បីផ្តល់បណ្ណ័កម្មសិទ្ធដីធ្លីសម្រាប់ជនជាតិដើមភាគតិចមានភាពយឺតយ៉ាវ។ ការសិក្សាបានបង្ហាញថាការប្រមូលអុសមិនមាននិរន្តភាព និងសកម្មភាពប្រើប្រាស់ដីទំហំតូច មិនមាននិរន្តភាព គឺជាកត្តាចម្បងដែលនាំឲ្យបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា។ ដូចនេះ យុទ្ធសាស្ត្ររេដបូកថជាតិអាចចូលរួមចំណែកដូចខាងក្រោមៈ<br>5. ការធ្វើឲ្យបានច្បាស់នូវសិទ្ធប្រើប្រាស់ដីធ្លី តាមរយៈការអភិវឌ្ឍន៍ និងការរក្សាកិច្ចព្រមព្រៀងប្រើប្រាស់ដីធ្លីជាមួយសហគមន៍មូលដ្ឋាន (ផែនការប្រើប្រាស់ដីឃុំ)<br>6. ជួយបង្កើនល្បឿនដល់ការផ្តួចផ្តើមដែលកំពុងអនុវត្តន៍ដោយរាជរដ្ឋាភិបាល ក្នុងការទទួលស្គាល់សិទ្ធិរបស់សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ តាមរយៈការធ្វើឲ្យមានភាពសមញ្ញនូវដំណើរការអនុម័តដ៏ស្មុគស្មាញ និងវែងអន្លាយនាពេលបច្ចុប្បន្ន ។<br>7. នៅទីកន្លែងដែលឥន្ធនៈមានប្រភពពីឈើ(អុស) មិនអាចអភិវឌ្ឍន៍ ឬ មិនអាចផ្គត់ផ្គង់ប្រកបដោយនិរន្តភាព ត្រូវណែនាំជម្រើសនានា ដែលអាចបន្ថយនូវការប្រើប្រាស់ថាមពលដែលមានប្រភពពីកាបូន(ស្នើសុំសម្រួលឃ្លា និងពាក្យពេចន៍)<br>8. ផ្តល់មុខរបរទ្រទ្រង់ជីវភាពរស់នៅដែលអាចកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើមានដូចជា៖<br>- ផ្តល់នូវសកម្មភាពផ្សព្វផ្សាយកសិកម្ម<br>- លើកកំពស់ប្រពលវប្បកម្មកសិកម្មចំពោះកសិដ្ឋានគ្រប់ខ្នាត<br>- បង្កើតគម្រោងទ្រទ្រង់ជីវភាពរស់នៅដោយផ្អែកលើអនុផលព្រៃឈើ |

| | | |
|---|---|---|
| | | - បង្កើតសកម្មភាព ដែលអាចរក ចំណូលដល់សហគមន៍មូលដ្ឋានដូចជាអេកូទេសចរណ៍ |
| | ភ្លើង | ការសិក្សាបានបង្ហាញថា ផលប៉ះពាល់ចំបងនៃភ្លើងព្រៃនៅប្រទេសកម្ពុជា បានបំផ្លាញនូវ ប្រភេទព្រៃស្រោង ដែលងាយរងគ្រោះដោយសារភ្លើង ដែលធ្វើឲ្យផ្ទៃដីព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងដ៏ធំធេង ប្រែក្លាយទៅជាតំបន់ព្រៃល្បោះ។ ដំណើរការនេះ កំពុងវិវត្តន៍ទៅមុខនៅក្នុងប្រទេសកម្ពុជា និងធ្វើឲ្យផ្ទៃដីព្រៃពាក់កណ្តាលស្រោងភាគច្រើនបំផុត បានប្រែក្លាយទៅជាតំបន់ព្រៃល្បោះ ធ្វើឲ្យបាត់បង់គុណភាពដី និងប្រែក្លាយដីទៅជាស្រទាប់រឹងដែលកាត់បន្ថយដីជាតិដី ជីវម៉ាស់ និងកាបូនស្តុកទាំងខាងលើ និងខាងក្រោមដី។ បច្ចុប្បន្ន បទបញ្ញត្តិ ដែលទាក់ទង នឹងភ្លើងព្រៃនៅប្រទេសកម្ពុជា មានគោលបំណងការពារកុំឲ្យភ្លើងឆេះព្រៃឈើ ទោះបីជានៅក្នុងច្បាប់ព្រៃឈើមានការអនុញ្ញាតឲ្យប្រើភ្លើងសម្រាប់ការថែទាំព្រៃឈើក៏ដោយ។ ជាមួយនិងការអភិវឌ្ឍយុទ្ធសាស្ត្ររេដបូកជាតិ នឹងឈរលើទស្សនៈផ្សេងៗសស្តីពីតួនាទីរបស់ភ្លើងព្រៃ ក្នុងការថែរក្សាកាបូនព្រៃឈើ ដែលទាមទារឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីធ្វើឲ្យគោលនយោបាយកាន់តែមានភាពសមស្រប។ នៅក្នុងពេលជាមួយគ្នានេះ យុទ្ធសាស្ត្ររេដបូកជាតិគួរផ្តោតទៅលើ៖<br>3. វិធានការណ៍ការពារភ្លើងឆេះព្រៃរួមមាន ការជម្រះយកចេញនូវឈើងាប់មួយចំនួន និងការកសាងផ្លូវភ្លើងសម្រាប់ការពារ ការរីករាលដាលនៃការដុតភ្លើង និងការឆេះព្រៃបណ្តាលមកពីកត្តាធម្មជាតិ<br>4. សិក្សាស្រាវជ្រាវបន្ថែមទៅលើឥទ្ធិពលនៃភ្លើងឆេះព្រៃដែលបណ្តាលមកពីកត្តាធម្មជាតិ និងមនុស្ស និងភាពញឹកញាប់នៃការ កើតឡើងភ្លើងព្រៃទៅលើដង់ស៊ីតេកាបូនព្រៃឈើ។ |
| | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | តាមការពិនិត្យមើលទៅលើស្ថានភាពបច្ចុប្បន្ននៃផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច និងដើម្បីបំពេញតម្រូវការថាមពលស្របតាមការរីកចំរើនផ្នែកសេដ្ឋកិច្ច។ ជាងនេះទៅទៀត យុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០១៣-២០១៨) បានបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដោយធានាបាននិរន្តភាពបរិស្ថាន។ ដោយសារមូលហេតុនេះ យុទ្ធសាស្ត្ររេដបូកជាតិ គួររួមចំណែកបំពេញការងារដូចខាងក្រោម៖<br>5. ផ្តល់ការគាំទ្រ (បច្ចេកទេស ហិរញ្ញវត្ថុ ច្បាប់) ដើម្បីពង្រឹងក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា អនុវត្តន៍ឲ្យមាន ប្រសិទ្ធភាពនូវច្បាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន(EIA)<br>6. ផ្តល់ការគាំទ្រ (បច្ចេកទេស ហិរញ្ញវត្ថុ ច្បាប់) ដើម្បីពង្រឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ក្នុងការអនុវត្តជំពូក ដែលមាននៅក្នុងច្បាប់ព្រៃឈើឆ្នាំ ២០០២ ស្តីពីប្រតិបត្តិការរុករករ៉ែក្នុងតំបន់ព្រៃអចិន្ត្រៃយ៍របស់រដ្ឋ<br>7. គាំទ្រឲ្យមានតម្លាភាព គណនេយ្យភាព និងធ្វើការពិគ្រោះយោបល់ឲ្យបានពេញលេញ និងមានប្រសទ្ធភាព និងការចូលរួមពីអ្នកពាក់ព័ន្ធទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់ព្រៃឈើ |

| | | |
|---|---|---|
| | | 8. លើកកម្ពស់ការទទួលបានព័ត៌មានជាសាធារណៈ និងការប្រកាសនានាដែលទាក់ទង និងផែនការ អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) |

## លទ្ធផលក្រុមបច្ចេកទេស MRV/FREL

| | |
|---|---|
| ការបំលែងដីព្រៃធម្មជាតិទៅជាដីមិនមែនព្រៃ<br>*(ទ្រង់ទ្រាយធំ)* | Economic Land Concession<br>• បន្តការផ្អាកផ្តល់ដី ELC<br>• ពង្រឹងយន្តការ EIA<br>• ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យា<br>• ត្រួតពិនិត្យការដេកហូតឈើ<br>Social Land Concession<br>• អនុវត្តន៍យន្តការ EIA<br>• ត្រួតពិនិត្យ និងវាយតម្លៃ ដី SLC មានស្រាប់<br>• ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP)<br>• ពង្រឹងបច្ចេកវិទ្យាត្រួតពិនិត្យ និងតាមដានការប្រែប្រួលការប្រើប្រាស់ដីព្រៃ |
| រុករានដីព្រៃខុសច្បាប់<br>(ចំណាកស្រុក) | • ពង្រឹងយន្តការតុលាការ<br>• ពង្រឹងគណៈកម្មការ/អនុគណៈកម្មការដោះស្រាយ ទប់ស្កាត់ និងលុបបំបាត់ការកាប់រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិ<br>• ផ្សព្វផ្សាយ/អប់រំកុំអោយកាប់ដីព្រៃខុសច្បាប់<br>• ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ឃុំ(CLUP)<br>• បង្កើនយន្តការដោះស្រាយបញ្ហាកង្វះខាតដី |
| តម្រូវការប្រើប្រាស់ឈើក្នុងស្រុក | • សិក្សាអំពីបរិមាណប្រើប្រាស់ឈើក្នុងស្រុក(ថ្នាក់ក្រោមជាតិ)<br>• បង្កើតចំការឈើសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក<br>• លើកទឹកចិត្តកែច្នៃឈើ ប្រើប្រាស់អោយអស់លទ្ធភាព<br>• សិក្សាប្រសិទ្ធភាពសេដ្ឋកិច្ចប្រភេទឈើនីមួយៗ<br>• ពង្រឹងយន្តការចុះបញ្ជី (ចំការឈើដាំ ដេប៉ូកែច្នៃឈើ សិប្បកម្មកែច្នៃ)<br>• សិក្សាអំពីប្រភពឈើផ្គត់ផ្គង់ក្នុងស្រុក |
| តម្រូវការប្រើប្រាស់ឈើថាមពល | • សិក្សាបរិមាណធ្យូងប្រើប្រាស់ប្រចាំឆ្នាំ (ថ្នាក់ក្រោមជាតិ)<br>• បង្កើតជម្រើសកែច្នៃធ្យូង ( Non Wood Energy)<br>• សិក្សាប្រភេទឈើថាមពល<br>• ជម្រុញយន្តការបង់ថ្លៃសេវាកម្មបរិស្ថាន ( Non Wood Energy)<br>• ជម្រុញការចូលរួមរបស់សហគមន៍ |

| |
|---|
| • ពង្រឹកយន្តការគ្រប់គ្រងដែលមានស្រាប់៖<br>➢ តំបន់ព្រៃការពារ<br>➢ សហគមន៍ព្រៃឈើ<br>➢ សហគមន៍នេសាទ<br>➢ សហគមន៍តំបន់ការពារ<br>• បង្កើតយន្តការបង្កើនជីវភាពសហគមន៍៖<br>➢ កម្មវិធីអភិវឌ្ឍន៍សហគមន៍<br>➢ អភិវឌ្ឍន៍អនុផលព្រៃឈើ<br>➢ អភិវឌ្ឍន៍កសិកម្ម |

**លទ្ធផលក្រុមបច្ចេកទេសប្រព័ន្ធជានាសុវត្ថិភាព៖**

| | |
|---|---|
| សម្បទានដី | • បន្តការផ្អាកការផ្តល់សម្បទានសេដ្ឋកិច្ច<br>• បន្តការត្រួតពិនិត្យការអនុវត្តកិច្ចសន្យារបស់សម្បទានសេដ្ឋកិច្ច<br>• ការត្រួតពិនិត្យនីតិវិធី និងវាយតម្លៃ<br>• ពង្រឹងការអនុវត្តអនុក្រឹត្យ ១៤៦ ស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច<br>• អនុវត្តន៍នីតិវិធីផ្តល់សម្បទានសេដ្ឋកិច្ច |
| ដីសម្បទានសង្គមកិច្ច | • បង្កើនប្រសិទ្ធភាពការអនុវត្តនិងការត្រួតពិនិត្យ អនុក្រឹត្យ<br>• ធ្វើផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត<br>• បង្កើនការចុះបញ្ជីរដ្ឋ<br>• លុបបំបាត់អ្នកតាំងទីលំនៅខុសច្បាប់<br>• បង្កើតការងារ និងមុខរបរផ្សេងៗ សម្រាប់សហគមន៍មូលដ្ឋាន |
| ការធ្វើអោយប្រសើរឡើងនូវកាបូនព្រៃឈើ និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព | • ស្តារព្រៃនៅតំបន់ដីព្រៃរេចរឹល<br>• ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាដីសាធារណៈរបស់រដ្ឋ តាមរយៈការធ្វើអនុប្រយោគ<br>• ពង្រឹងគោលនយោថ្នាក់ជាតិពាក់ព័ន្ធ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយបញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ |

<u>**(ឧបសម្ព័ន្ធ ။)**</u>

**ប្រធានបទ:** ក្រុមពិភាក្សា ស្តីពី សារៈប្រយោជន៍ និងហានីភ័យដែលអាចកើតមានពីការអនុវត្តសកម្មភាព/គោលនយោបាយ និងវិធាននៅក្នុងការដោះស្រាយបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើដែលបានស្នើឡើង

## លទ្ធផលក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍៖

| | |
|---|---|
| ១.ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្រ្តប្រើប្រាស់ដីច្បាស់លាស់ | |
| • កាត់បន្ថយការបំភាយឧស្ម័ន $CO_2$ និងបង្កើនកាបូនស្តុក<br>• កាត់បន្ថយការបាត់បង់ព្រៃឈើ<br>• កាត់បន្ថយទំនាស់ការប្រើប្រាស់ដី | • ប៉ះពាល់ដល់ការវិនិយោគលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម |
| ២. ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច | |
| • កាត់បន្ថយការបាត់បង់ព្រៃឈើ<br>• បង្កើនប្រសិទ្ធភាពនៃការអនុវត្ត ELC | N/A |
| ៣. កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចអោយបានច្បាស់លាស់នៅទីវាល | |
| • ងាយស្រួលដល់ការគ្រប់គ្រង និងកាត់បន្ថយទំនាស់<br>• ទប់ស្កាត់ការបាត់បង់ព្រៃឈើ | • ទំនាស់លើកម្មសិទ្ធដីធ្លី ?<br>ចំណាយថវិកា |
| ៤. បង្កើនប្រសិទ្ធភាពការអនុវត្ត និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩ (សម្បទានដីសង្គមកិច្ច) | |
| • កាត់បន្ថយការរានដីព្រៃ<br>• មានកម្មសិទ្ធដីធ្លីស្របច្បាប់ | N/A |
| ៥. ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP) | |
| • បង្កើនសុវត្ថិភាពដីធ្លី<br>• កាត់បន្ថយការបាត់បង់ព្រៃឈើ | N/A |
| ៦. ពង្រឹងបច្ចេកវិទ្យាត្រួតពិនិត្យ និងតាមដានការប្រែប្រួលការប្រើប្រាស់ដីព្រៃ | |
| • ដឹងអំពីការវិវត្តន៍នៃការបាត់បង់ព្រៃនិងការកើនឡើងនៃព្រៃឈើ<br>• ងាយស្រួលតាមដាន គ្រប់គ្រងនិងទប់ស្កាត់ការបាត់បង់ព្រៃឈើ | • ការចំណាយថវិកាជាតិ |
| ៧. ស្តារព្រៃនៅតំបន់ដីរេចរឹល | |
| • រក្សា និងបង្កើនប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងគម្របព្រៃឈើ<br>• ចូលរួមការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ<br>• បង្កើនផលប្រយោជន៍ដល់សហគមន៍<br>• បង្កើនការបូនស្តុក<br>• ទប់ស្កាត់ការហូរច្រោះ និងការពារខ្យល់ព្យុះ | • ចំណាយថវិកា |
| ៨. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ រឺ សហគមន៍នេសាទ | |
| • រក្សា និងបង្កើនប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងគម្របព្រៃឈើ<br>• ចូលរួមការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ<br>• បង្កើនផលប្រយោជន៍ដល់សហគមន៍<br>• បង្កើនការបូនស្តុក<br>• ទប់ស្កាត់ការហូរច្រោះ និងការពារខ្យល់ព្យុះ<br>• បង្កើនការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការ | N/A |

| | |
|---|---|
| គ្រប់គ្រងព្រៃឈើ | |
| ៩. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាតំបន់ការពារធម្មជាតិរឺព្រៃការពារ | |
| • រក្សា និងបង្កើនប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងគម្របព្រៃឈើ<br>• ចូលរួមការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ<br>• បង្កើនផលប្រយោជន៍ដល់សហគមន៍<br>• បង្កើនការបូនស្តុក<br>• ទប់ស្កាត់ការហូរច្រោះ និងការពារខ្យល់ព្យុះ | N/A |
| ១០. ពង្រឹង**ការអនុវត្ត**គោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ **និង ផែនការថ្នាក់ជាតិ** និងថ្នាក់ក្រោមជាតិ | |
| ១១. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ឈើខុសច្បាប់ | |
| • រក្សា និងបង្កើនប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងគម្របព្រៃឈើ<br>• ចូលរួមការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ<br>• បង្កើនផលប្រយោជន៍ដល់សហគមន៍<br>• បង្កើនការបូនស្តុក<br>• ទប់ស្កាត់ការហូរច្រោះ និងការពារខ្យល់ព្យុះ | N/A |
| ១២. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ទន្ទ្រានយកដីព្រៃជាកម្មសិទ្ធិ | |
| • រក្សា និងបង្កើនប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ និងគម្របព្រៃឈើ<br>• ចូលរួមការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ<br>• បង្កើនផលប្រយោជន៍ដល់សហគមន៍<br>• បង្កើនការបូនស្តុក<br>• កាត់បន្ថយទំនាស់ | N/A |
| ១៣. បង្កើតចំការឈើដាំសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក | |
| • កាត់បន្ថយសម្ពាធនៃការប្រើប្រាស់ព្រៃធម្មជាតិ<br>• បង្កើនគម្របព្រៃឈើ<br>• ធ្វើឲ្យបរិស្ថានមានភាពប្រសើរឡើង<br>• កាត់បន្ថយចំណាយ និងបង្កើនចំណូល | N/A |
| ១៤. បង្កើតជម្រើសផ្សេងៗក្នុងការកាត់បន្ថយសម្ពាធលើការប្រើប្រាស់អុសនិង ធ្យូង | |
| • កាត់បន្ថយការរេចរឹលព្រៃឈើ | N/A |

## លទ្ធផលក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដបូក៖

| សកម្មភាពរេដបូក | សារៈប្រយោជន៍ | ហានិភ័យ |
|---|---|---|

| | | |
|---|---|---|
| ១. ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្រ្តប្រើប្រាស់ដីច្បាស់លាស់ | • មិនប៉ះពាល់ដល់គម្របព្រៃឈើ ព្រៃលិចទឹក កោងកាង<br>• មិនប៉ះពាល់បរិស្ថាន និងសង្គម | • បាត់បង់ចំណូលរដ្ឋ<br>• បាត់បង់ដីដោយការកាប់ ទន្រ្ទានយកខុសច្បាប់ |
| ២. ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច | • ក្រុមហ៊ុនអនុវត្តន៍ទៅតាមផែនការមេ និងកិច្ចសន្យា<br>• កាត់បន្ថយបទល្មើស<br>• បង្កើនប្រសិទ្ធភាពការអនុវត្ត | • ចំនួនក្រុមហ៊ុនអាចថយចុះ |
| ៣. កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចអោយបានច្បាស់លាស់នៅទីវាល | • កាត់បន្ថយទំនាស់ដីធ្លី | |
| ៤. បង្កើនប្រសិទ្ធភាពការអនុវត្ត និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩ (សម្បទានដីសង្គមកិច្ច) | • អនុវត្តចំទិសដៅ(កាត់បន្ថយភាពក្រីក្រ)<br>• កាត់បន្ថយការបាត់បង់ព្រៃ | |
| ៥. ~~ពង្រឹងការអនុវត្ត~~បង្កើតផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP) (ទូទាំងខេត្ត) | • កាត់បន្ថយទំនាស់ដីធ្លី<br>• បង្កើនចំណូលពីការបង់ពន្ធ<br>• ស្គាល់ពីប្រភេទដីច្បាស់លាស់ងាយស្រួលក្នុងការអភិវឌ្ឍ | • ពិបាកក្នុងការផ្លាស់ប្តូរប្រភេទដី |
| ៦. ពង្រឹងបច្ចេកវិទ្យាត្រួតពិនិត្យ និងតាមដានការប្រែប្រួលការប្រើប្រាស់ដីព្រៃ | • កាត់បន្ថយបទល្មើសនិងការបាត់បង់ដីព្រៃឈើ | • ចំណាយថវិកាច្រើន |
| ៧. ស្តារព្រៃនៅតំបន់ដីរេចរឹល | • បង្កើនគម្របព្រៃឈើ និងជីវៈចម្រុះ<br>• កាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• កាត់បន្ថយភាពក្រីក្រ | • ចំណាយថិកាច្រើន |
| ៨. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ រឺ សហគមន៍នេសាទ | កាត់បន្ថយភាពក្រីក្រ<br>ផ្តល់ឱកាសការងារដល់សហគមន៍<br>បង្កើនគម្របព្រៃឈើ | • សមត្ថភាព និងថវិកា នៅមានកម្រិត<br>• លំបាកក្នុងការទប់ស្កាត់បទល្មើសផ្សេងៗ<br>• |
| ៩. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជា តំបន់ការពារ រឺ ព្រៃការពារ | • បង្កើនគម្របព្រៃឈើនិងជីវៈចម្រុះ<br>• ចំណូលជាតិ (ទេសចរធម្មជាតិ)<br>• ជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• បង្កើនកាបូនស្តុក | • បាត់ចំណូលថវិកាជាតិ (ពន្ធពីក្រុមហ៊ុនវិនិយោគ) |

| | | |
|---|---|---|
| ១០. ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | • ថ្នាក់ក្រោមជាតិមានថវិកាក្នុងការគ្រប់គ្រងព្រៃឈើ ព្រៃលិចទឹក ព្រៃកោងកាង ដោយមានការចូលរួម<br>• បង្កើនសមត្ថភាពក្នុងការគ្រប់គ្រងព្រៃឈើដោយសហគមន៍<br>• មានគោលនយោបាយគ្រប់គ្រងព្រៃឈើដោយសហគមន៍ | • ចំណាយថវិកាច្រើន |
| ១១. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ឈើខុសច្បាប់ | • កាត់បន្ថយបទល្មើស<br>• បង្កើនគម្របព្រៃ<br>• ពង្កើនចំណូល | • ឈើឡើងថ្លៃ<br>• ខ្វះឈើថាមពលប្រើប្រាស់ |
| ១២. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ទន្ទ្រានយកដីព្រៃជាកម្មសិទ្ធ | • ថែរក្សាបានគម្របព្រៃ<br>• កាត់បន្ថយបទល្មើស<br>• កាត់បន្ថយការតាំងទីលំនៅខុសច្បាប់ | • បង្កើនចំណាយ |
| ១៣. បង្កើតចំការឈើសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក | • កាត់បន្ថយការកាប់ឈើធម្មជាតិ<br>• បង្កើនគម្របព្រៃ | • ចំណាយថវិកា<br>• ទីតាំងដីសម្រាប់ដាំ<br>• អាចប៉ះពាល់ដល់ព្រៃធម្មជាតិ |
| ១៤. បង្កើតជម្រើសផ្សេងៗក្នុងការកាត់បន្ថយសំពាធលើការប្រើប្រាស់អុសនិងធ្យូង | • កាត់បន្ថយការកាប់ឈើធម្មជាតិ<br>• បង្កើនគម្របព្រៃ | • ប្រជាជនអាចមិនទទួលយក |

## លទ្ធផលក្រុមការងារបច្ចេកទេសអនុវត្តវេជបូកគំរូ៖

<table>
<tr><td colspan="2">១. ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្ត្រប្រើប្រាស់ដីច្បាស់លាស់</td></tr>
<tr><td colspan="2">២. ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច</td></tr>
<tr><td colspan="2">៣. កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចអោយបានច្បាស់លាស់នៅទីវាល</td></tr>
<tr><td colspan="2">៤. បង្កើនប្រសិទ្ធភាពការអនុវត្ត និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩ (សម្បទានដីសង្គមកិច្ច)</td></tr>
<tr><td colspan="2">៥. ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP)</td></tr>
<tr><td colspan="2">៦. ពង្រឹងបច្ចេកវិទ្យាត្រួតពិនិត្យ និងតាមដានការប្រែប្រួលការប្រើប្រាស់ដីព្រៃ</td></tr>
<tr><td colspan="2">៧. ស្តារព្រៃនៅតំបន់ដីរេចរឹល</td></tr>
<tr><td colspan="2">៨. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ រឺ សហគមន៍នេសាទ</td></tr>
<tr><td>• បង្កើនការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ</td><td>• អាចបង្កអោយមានជំលោះក្នុងសហគមន៍<br>• អាចមានការចាប់ទន្ទ្រានយកដីកម្មសិទ្ធខុសច្បាប់</td></tr>
</table>

| | |
|---|---|
| • មានសិទ្ធកាន់កាប់ គ្រប់គ្រង និងបង្កើនចំណូល | • មានជនឆ្លៀតឱកាស |
| ៩. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជា តំបន់ការពារធម្មជាតិ រឺ ព្រៃការពារ | |
| • បង្កើនធនធានព្រៃឈើឡើងវិញ | • អាចមានការចាប់ទន្ទ្រានយកដីកម្មសិទ្ធខុសច្បាប់<br>• បាត់បង់ចំណូលថវិកាជាតិ<br>ចំណាយថវិកាជាតិសម្រាប់ការស្តារព្រៃឡើងវិញ |
| ១០. ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | |
| • ធានាសុវត្ថិភាព និងសិទ្ធិប្រើប្រាស់សហគមន៍ដែលរស់ពឹងអាស្រ័យលើព្រៃឈើ<br>• បង្កើនតម្លាភាព<br>• លើកកម្ពស់ការទទួលស្គាល់សិទ្ធរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ<br>• លទ្ធភាពទទួលបានការគាំទ្រទាំងមធ្យោបាយ និងថវិកាសម្រាប់ការការពារធនធានធម្មជាតិ | • អាចបង្កអោយមានជំលោះក្នុងសហគមន៍<br>តម្រូវការថវិកាជាតិមានការកើនឡើង |
| ១១. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ឈើខុសច្បាប់ | |
| • ធានានិរន្តភាព និងការការពារជីវចម្រុះ<br>• បង្កើនចំណូលថវិកាជាតិ<br>កើនឡើងអនុផលព្រៃឈើ និងជីវភាពសហគមន៍ប្រសើរឡើង | • បាត់បង់មុខរបរ និងប្រាក់ចំណូល<br>• ធ្វើអោយមានចំណាកស្រុក<br>• បង្កគ្រោះថ្នាក់ដល់មន្ត្រីអនុវត្តន៍ច្បាប់ |
| ១២. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ទន្ទ្រានយកដីព្រៃជាកម្មសិទ្ធ | |
| • បង្កើនការយល់ដឹងពីច្បាប់<br>• ធានាបាននូវការចូលរួមការពារព្រៃឈើ<br>• ដោះស្រាយជម្លោះក្នុងតំបន់ដីព្រៃ | • អាចមានទំនាស់ជាមួយនឹងទំនៀមទំលាប់ប្រពៃណី<br>• អាចបង្កអោយមានជម្លោះ ដោយសារប្រជាពលរដ្ឋមិនបានយល់ ឬ មិនទទួល ស្គាល់ពីការអនុវត្តច្បាប់<br>• បង្កគ្រោះថ្នាក់ដល់មន្ត្រីអនុវត្តន៍ច្បាប់ |
| ១៣. បង្កើតចំការឈើសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក | |
| • ផ្តល់ចំណូលបន្ថែម<br>• កាត់បន្ថយសម្ពាធលើព្រៃឈើ<br>• បង្កើនគម្របព្រៃឈើ<br>បង្កើនចំណេះដឹងពីសារៈប្រយោជន៍ព្រៃឈើ | • តម្រូវការរយៈពេលវែង<br>• អាចមិនឆ្លើយតបទៅនឹងតម្រូវការទីផ្សារ<br>• អាចបង្កអោយមានការកាប់ឆ្ការដីព្រៃធម្មជាតិដើម្បីបង្កើតចំការដាំឈើ<br>• គ្មានទីផ្សារច្បាស់លាស់ |
| ១៤. បង្កើតជម្រើសផ្សេងៗក្នុងការកាត់បន្ថយសម្ពាធលើការប្រើប្រាស់អុសនិង ធ្យូង | |

| | |
|---|---|
| • ចំណេញពេលវេលា និងថវិកា<br>• បង្កើនកម្រិតជីវភាពរស់នៅ<br>• កាត់បន្ថយគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុ | • ចំណេះដឹង និងសមត្ថភាពរួមទាំងធនធានហិរញ្ញវត្ថុសម្រាប់ទទួលបាននូវបច្ចេកវិទ្យា<br>• បាត់មុខរបរលក់អុស ធ្យូង |

**លទ្ធផលក្រុមការងារបច្ចេកទេស MRV/FREL៖**

| | |
|---|---|
| ១. ពន្យារពេលនៃការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់មានយុទ្ធសាស្រ្តប្រើប្រាស់ដីច្បាស់លាស់ | |
| • កាត់បន្ថយការបាត់បង់ព្រៃឈើ<br>• បង្កើនជម្រកសត្វព្រៃ និងជីវចម្រុះ<br>• ចូលរួមចំណែកវិស័យទេសចរណ៍<br>• កាត់បន្ថយការប្រែប្រួលអាកាសធាតុ ការហូរច្រោះ និងជម្លោះដីធ្លី<br>• រក្សាសក្តានុពលកក្នុងការប្រមូលអនុផល បង្កើនប្រាក់ចំណូលសហគមន៍ | • ខ្វះការផ្គត់ផ្គង់ឈើក្នុងស្រុកបណ្តាលអោយមានកាប់ឈើខុសច្បាប់ក្នុងតំបន់ការពារ<br>• កាត់បន្ថយមុខរបររបស់ប្រជាពលរដ្ឋមូលដ្ឋាន<br>• បាត់បង់ចំណូលរដ្ឋ |
| 2. ត្រួតពិនិត្យការអនុវត្តផែនការមេ និងរឹតបន្តឹងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច | |
| • ចូលរួមចំណែកធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចគ្រប់គ្រងព្រៃឈើ<br>• ទាក់ទាញ និងជម្រុញការវិនិយោគ<br>• ជួយជម្រុញដល់ការអនុវត្តផែនការមេអោយកាន់តែមានប្រសិទ្ធភាព<br>• បង្កើនចំណូលរដ្ឋ | • គ្មាន |
| ៣. កំណត់ និងបោះបង្គោលព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចអោយបានច្បាស់លាស់នៅទីវាល | |
| • ទប់ស្កាត់ការកាប់រានព្រៃឈើខុសច្បាប់<br>• មានព្រំប្រទល់ដែនព្រៃច្បាស់លាស់ | • ជម្លោះដីធ្លី រវាងម្ចាស់ដីសម្បទាន និងប្រជាពលរដ្ឋ |
| ៤. បង្កើនប្រសិទ្ធភាពគ្រប់គ្រង និងការត្រួតពិនិត្យនៃអនុក្រឹត្យលេខ១៩ (សម្បទានដីសង្គមកិច្ច) | |
| • ទប់ស្កាត់ការកាប់រានព្រៃឈើខុសច្បាប់(ដោយជុំៗ) ដើម្បីសង់លំនៅដ្ឋាន | • បាត់បង់ជីវចម្រុះ និងព្រៃឈើ (មិនអនុវត្ត EIA) |
| ៥. ពង្រឹងការអនុវត្តផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (PLUP) | |
| • មានកម្មសិទ្ធប្រើប្រាស់ដីធ្លីច្បាស់លាស់ | • អាចកើតមានជម្លោះនៅពេលរៀបចំផែនការ |
| ៦. ស្តារព្រៃនៅតំបន់ដីរេចរឹល | |
| • បង្កើនគម្របព្រៃឈើ និងជម្រកសត្វ | • នាំប្រភេទឈើក្រៅស្រុកចូល |
| ៨. ប្រែក្លាយដីសម្បទានសេដ្ឋកិច្ចដែលបានដកហូត មកជាការគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ រឺ សហគមន៍នេសាទ | |

<table>
<tr><td>• បង្កើនការប្រមូលអនុផល និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ<br>• មានលទ្ធភាពស្តារព្រៃឈើឡើងវិញ<br>• បង្កើនការផ្គត់ផ្គង់ឈើប្រើប្រាស់ក្នុងស្រុក(តាមរយៈការដកហូតតាមបច្ចេកទេស)</td><td>• ផ្ទៃដីដែលដកហូតមានទំហំធំ សហគមន៍មិនអាចគ្រប់គ្រងបានល្អ</td></tr>
<tr><td colspan="2">១០. ពង្រឹងគោលនយោបាយថ្នាក់ជាតិពាក់ពន្ធ័នឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ក៏ដូចជាការស្វែងរកមធ្យោបាយ បញ្ចូលការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ចូលទៅក្នុងគោលនយោបាយ ការវិនិយោគ និងផែនការថ្នាក់ជាតិ  និងថ្នាក់ក្រោមជាតិ</td></tr>
<tr><td></td><td>-គ្មាន</td></tr>
<tr><td colspan="2">១១. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ឈើខុសច្បាប់<br>១២. ពង្រឹងការអនុវត្តច្បាប់ទាក់ទងការកាប់ទន្ទ្រានយកដីព្រៃជាកម្មសិទ្ធ</td></tr>
<tr><td>• កាត់បន្ថយការបាតបង់ព្រៃឈើ និងបង្កើនជីវចម្រុះ<br>• ផ្តល់ប្រយោជន៍ដល់បរិស្ថាន<br>• បង្កើនប្រាក់ចំណូល តាមរយៈការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តភាព</td><td>• វិវាទអាចកើមាន នៅពេលអនុវត្តន៍ច្បាប់<br>• អ្នកមានបុណ្យស័ក្តិ និងអំណាររួចផុតពីការជាប់ទោស រឺ មិនត្រូវគោរពច្បាប់</td></tr>
<tr><td colspan="2">១៣. បង្កើតចំការឈើសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក</td></tr>
<tr><td></td><td>• នាំប្រភេទឈើក្រៅស្រុកចូល និងអាចនាំជំងឺ ចម្លងដល់ប្រភេទក្នុងស្រុក</td></tr>
<tr><td colspan="2">១៤. បង្កើតជម្រើសផ្សេងៗក្នុងការកាត់បន្ថយសម្ពាធលើការប្រើប្រាស់អុសនិង ធ្យូង</td></tr>
<tr><td></td><td></td></tr>
</table>

<u>(ឧបសម្ព័ន្ធ III)</u>

## <u>បទបង្ហាញ ដែលបានដកស្រង់ចេញពីយុទ្ធសាស្រ្តរេដបូកជាតិ ក្នុងសេចក្តីព្រាងលើកទី៣</u>

**Cambodia REDD+ National Programme**
UNDP PROJECT No. 00076292
(#40, Preah Norodom Blvd, Khan Daun Penh, Phnom Penh, Kingdom of Cambodia, 3th Floor)

---

# កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី២

## ប្រវត្តិ

យុទ្ធសាស្ត្ររេដបូកជាតិ គឺជាឯកសារគោលនយោបាយដ៏សំខាន់មួយដែលផ្ដល់នូវទិសដៅយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់អនុវត្តសកម្មភាពរេដបូក។ ដូចជាយុទ្ធសាស្ត្រផ្សេងៗទៀតដែរ យុទ្ធសាស្ត្ររេដបូកជាតិនឹងកំណត់នូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ និងរៀបចំគោលនយោបាយដ៏សាកសម និងមានវិធានចាំបាច់មួយចំនួន ដើម្បីកាត់បន្ថយនូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ ដែលសកម្មភាពទាំងនេះនឹងឈានទៅដល់ការវាស់នូវបរិមាណនៃកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអភិរក្ស និងការបង្កើនបរិមាណសន្និធិកាបូនដែលផ្ទុកនៅក្នុងព្រៃ។

យោងតាមការសម្រេចរបស់ប្រទេសជាភាគីនៃក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) ជាពិសេសកិច្ចព្រមព្រៀងនិងក្របខណ្ឌការងាររេដបូកដូចជា៖ កិច្ចព្រមព្រៀង ខេនខូន (CANCUN) និងក្របខណ្ឌវ៉ស៊័រ(WARSAR) បានកំណត់ថា យុទ្ធសាស្ត្ររេដបូកជាតិគឺជាតម្រូវការដំបូងបង្អស់សម្រាប់ប្រទេសដែលចង់អនុវត្តរេដបូក ដើម្បីអាចនឹងឈានទៅដល់ការទទួលបានការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល (Result-based finance) សម្រាប់ការអនុវត្តគោលនយោបាយ និងវិធានរេដបូក។ តម្រូវការសំខាន់ផ្សេងទៀត សម្រាប់ការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផលរួមមាន៖ ឯកសារជាតិស្តីពីប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ(National Forest Monitoring System) កំរិតបំភាយយោង(Reference Emission Level) និងប្រព័ន្ធព័ត៌មានប្រព័ន្ធធានាសុវត្ថិភាពរេដបូក (Safeguards Information System) ។

គោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជាគឺតម្រូវឲ្យមានយុទ្ធសាស្ត្ររេដបូកមួយដែលមានហត្ថលេខាទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និងបន្ទាប់មកនឹងមានការទទួលស្គាល់ពីសម្តេចនាយករដ្ឋមន្ត្រី មុនពេលកិច្ចប្រជុំប្រទេសជាភាគីនៅទីក្រុងប៉ារីស ក្នុងខែធ្នូ ឆ្នាំ២០១៥។

ដោយហេតុថា យុទ្ធសាស្ត្ររេដបូកជាតិ នឹងដាក់អោយអនុវត្តនៅក្នុងវិស័យព្រៃឈើ និងវិស័យដែលមានការពាក់ព័ន្ធនឹងព្រៃឈើ ដូចនេះទស្សនៈរបស់អ្នកពាក់ព័ន្ធ គួរតែរួមបញ្ចូលទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ដូច្នេះវាជាកិច្ចការមួយដ៏មានសារៈសំខាន់ណាស់ ដែលអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានឱកាសគ្រប់គ្រាន់ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ នឹងកែសម្រួលសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ មុនពេលយុទ្ធសាស្ត្រនេះត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល។ លើសពីនេះទៅទៀត ដើម្បីឲ្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិទទួលបានជោគជ័យគឺតម្រូវអោយមានការគាំទ្រ និងការចូលរួមពេលលេញពីអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី១ ត្រូវបានរៀបចំឡើង។ សេចក្តីព្រាងឯកសារនេះបានផ្ញើរជូនក្រុមអ្នកជំនាញការរេដបូកជាតិ និងអន្តរជាតិដែលសមាជិកចំនួន១១នាក់ ដើម្បី ពិនិត្យ និងផ្តល់យោបល់កែលម្អ។ លើសពីនេះ សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ ក៏បានផ្ញើរជូនផងដែរ ដល់អ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់កែសម្រួល។ គ្រប់មតិយោបល់ និងអនុសាសន៍ ដែលបានផ្តល់ដោយក្រុមអ្នកជំនាញការ ក៏ដូចជាមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានកត់ត្រា ពិចារណាដាក់បញ្ចូល និងកែសម្រួល ដើម្បីរៀបចំជាសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី២។ បន្ថែមពីលើនេះ ប្រវត្តិឯកសារ ក៏បានរៀបចំទន្ទឹមគ្នានឹងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិនេះផងដែរ។ ប្រវត្តិឯកសារនេះគឺផ្តោតសំខាន់លើការកត់ត្រា និងចងក្រងនូវគ្រប់មតិយោបល់ និងអនុសាសន៍របស់អ្នកពាក់ព័ន្ធ និងចំណុចសំខាន់ៗដែលបានឆ្លើយតបនឹងអនុសាសន៍ និងយោបល់ទាំងនោះ។

យោងតាមកិច្ចពិភាក្សាជាមួយមន្ត្រីរាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ និងផែនការដែលបានកំណត់ថា ប្រទេសកម្ពុជាយើងគួរមានសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយ ឲ្យបានមុនកិច្ចប្រជុំប្រទេសជាភាគីលើកទី

២១ នៅទីក្រុងប៉ារីស ដូច្នេះសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៣ ត្រូវរៀបចំឲ្យបាននៅតំណាច់ខែមិថុនា និងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៤ ត្រូវរៀបចំឲ្យបានរួចរាល់នៅខែកក្កដា និងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយ ត្រូវរៀបចំឲ្យបានសម្រេចនៅក្នុងខែសីហា ឆ្នាំ២០១៥។

ដូចនេះហើយ ក្នុងអំឡុងពេលនៃខែឧសភា និងខែសីហា ឆ្នាំ២០១៥ យុទ្ធសាស្ត្ររេដបូកជាតិ និងចំណុចដែលត្រូវគូសបញ្ជាក់នៅក្នុងឯកសារប្រវត្តិ នឹងត្រូវយកមកពិគ្រោះយោបល់ជាមួយក្រុមអ្នកពាក់ព័ន្ធដូចជា៖ ក្រុមការងាររេដបូកកម្ពុជា ក្រុមបច្ចេកទេសរេដបូកទាំង៤ក្រុម (ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ចែករំលែកផលប្រយោជន៍ ត្រួតពិនិត្យរាយការណ៍ និងផ្ទៀងផ្ទាត់ និងក្រុមអនុវត្តគម្រោងគំរូ)ក្រុមប្រឹក្សាយោបល់រេដបូក ក្រុមយេនឌ័ររេដបូក និងអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំពិគ្រោះយោបល់នេះនឹងប្រើប្រាស់ជាវេទិកាសម្រាប់អ្នកពាក់ព័ន្ធនានាដើម្បីផ្តល់ជំនាញបច្ចេកទេសរបស់ពួកគេ និងក្តីបារម្មណ៍របស់ពួកគេទៅលើយុទ្ធសាស្ត្រ រេដបូកជាតិ។ សូមបញ្ជាក់ថា នៅគ្រប់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ នឹងមានការកត់ត្រា ចងក្រងជាឯកសារដែលនឹងដាក់បញ្ចូលនៅក្នុងប្រវត្តិឯកសារ ដើម្បីធានាថាដំណើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ មានតម្លាភាព និងមានការទទួលខុសត្រូវ។

### ព័ត៌មានទូទៅដែលមាននៅក្នុងមាតិកាសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ

សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី២ បានរៀបចំឡើងដោយចែកចេញជា ០៩ផ្នែក៖

**ផ្នែកទី១៖** ការណែនាំពីយន្តការរេដបូក និងអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងការវិវឌ្ឍន៍នៃការរៀបចំយន្តការរេដបូកនៅក្នុងប្រទេសកម្ពុជា

**ផ្នែកទី២៖** ផ្តល់នូវព័តមានសង្ខេបនៃការគ្រប់គ្រងដីព្រៃនៅក្នុងប្រទេសកម្ពុជា បុព្វហេតុដែលបង្កអោយមានការបាត់បង់ព្រៃឈើ និងរេចរិលព្រៃឈើ និងគោលនយោបាយ និងវិធានដែលមានស្រាប់ក្នុងការដោះស្រាយបុព្វហេតុទាំងនេះ។ ផ្នែកនេះសន្និដ្ឋានដោយគូសបញ្ជាក់ថា រេដបូកជាតម្រូវការចាំបាច់ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ និងវិធានដែលមានស្រាប់នេះ។

**ផ្នែកទី៣៖**បង្ហាញពីគោលបំណងសំខាន់ ទិសដៅ និងគោលការណ៍ ដែលស្ថិតនៅក្រោមការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ ផ្នែកនេះក៏បានចងក្រងនូវការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងផែនការពិគ្រោះយោបល់ផងដែរ។

**ផ្នែកទី៤៖**ស្នើឡើងពីការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ គួតែចែកចេញជាបីដំហាន (១)ដំហាននៃការត្រៀមខ្លួន ដែលគេនឹងរំពឹងថានឹងបញ្ចប់នៅចុងឆ្នាំ២០១៥, (២)ដំហាននៃការអនុវត្ត រឺ ដំហានទី២ (២០១៦-២០២០) ដែលដំហាននេះ គោលនយោបាយ និងវិធាន/សកម្មភាពដែលបានកំណត់រួចនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវធ្វើ ការសាកល្បងអនុវត្ត និង (៣)ដំហាននៃការទូទាត់សងផ្អែកលើលទ្ធផល រឺ ដំហានទី៣ (នឹងចាប់ផ្តើមពីឆ្នាំ២០២១) ដែលនឹងផ្អែកលើការអនុវត្តលើយុទ្ធសាស្ត្ររេដបូកជាតិផ្ទាល់តែម្តង។

**ផ្នែកទី៥៖** ពិព៌ណនាថាតើប្រទេសកម្ពុជានឹងធានាថា ប្រព័ន្ធធានាសុវត្ថិភាពខេនខូនត្រូវបានដោះស្រាយ និងគោរព តាមរយៈការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ដែលបង្ហាញតាមរយៈការរៀបចំប្រព័ន្ធព័ត៌មាននៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក (SIS)។ ផ្នែកនេះនឹងដោះស្រាយគោលនយោបាយដែលមានស្រាប់សម្រាប់យន្តការដោះស្រាយទំនាស់ដែលស្ថិតក្រោមយុទ្ធសាស្ត្ររេដបូកជាតិ។

**ផ្នែកទី៦៖** ស្នើឡើងនូវការគ្រប់គ្រងហិរញ្ញប្បទានសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ។ ជាទូទៅ វាបង្ហាញនូវការស្នើឡើងមូលនិធិរេដបូកកម្ពុជា និងអភិបាលកិច្ចនៃការគ្រប់គ្រងមូលនិធិនេះ។

**ផ្នែកទី៧៖** ផ្តោតទៅលើកាពិភាក្សាដែលទាក់ទងនឹងប្រព័ន្ធត្រួតពិនិត្យធនធានព្រៃឈើ។ ផ្នែកនេះក៏បានរួមការពិព៌ណនាផ្នែកទាំងបួននៃប្រព័ន្ធត្រួតពិនិត្យធនធានព្រៃឈើ។ (១)ប្រព័ន្ធត្រួតពិនិត្យដីផ្នែកផ្កាយរណប (២)សារពើភណ្ឌព្រៃឈើជាតិ និង(៣)របាយការណ៍ឧស្ម័នផ្ទះកញ្ចក់។

**ផ្នែកទី៨៖** ពិព៌ណនាពីដំណើដែលកំពុងបន្តរៀបចំកំរិតបំភាយយោងដែលចេញមកពីព្រៃឈើ នៅក្នុងប្រទេសកម្ពុជា។ ផ្នែកនេះជាពិសេសផ្តោតលើការគណនាបរិមាណការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ឬ បង្កើនការស្រូបឧស្ម័នផ្ទះកញ្ចក់តាមរយៈការអនុវត្តគោលនយោបាយ និងវិធាន វិសកម្មភាពដែលបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។

**ផ្នែកទី៩៖** ស្នើនូវការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ។ ផ្នែកនេះបានស្នើឡើងនូវតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ផ្នែកនេះក៏ពិភាក្សាផងដែរនូវការៀបចំស្ថាប័នសម្រាប់ការអនុវត្តរេដបូកថ្នាក់ក្រោមជាតិ។

## គោលបំណង

គោលបំណងជាក់លាក់នៃកិច្ចប្រជុំពិគ្រោះយោបល់ ផ្អែកទៅលើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្ររេដបូកជាតិទាំងមូល ឬ ផ្នែកណាមួយ ដែលនឹងលើកយកមកពិគ្រោះយោបល់។ ជាទូទៅ កិច្ចប្រជុំពិគ្រោះយោបល់លើយុទ្ធសាស្ត្ររេដបូកជាតិនីមួយៗគឺមានគោលបំណង៖

- បង្ហាញពីស្ថានភាពនៃការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ដំណើការ និងគូសបញ្ជាក់នូវធាតុចូលដែលជាតម្រូវការ ឬ ការសម្រេចចិត្ត
- ប្រមូលធាតុដែលមានលក្ខណៈបច្ចេកទេស និងក្តីបារម្មណ៍ជាទូទៅពីអ្នកពាក់ព័ន្ធ និងអ្នកបច្ចេកទេសដែលបានចូលរួម និងបន្ទាប់មកដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ។
- កំណាត់តម្រូវការដែលជាធាតុចូលបន្ថែមទៀតដើម្បីកែសម្រួលសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ។

លទ្ធផលរំពឹងទុកនៃកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី២ (បានរៀបចំនៅ ថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០១៥ នៅខេត្តព្រះសីហនុ)

ប្រធានបទសំខាន់ដែលនឹងពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី២ មានដូចខាងក្រោមនេះ

**១. វិសាលភាព និងទំហំ**

**ក. សំនួរគោល៖** តើយុទ្ធសាស្ត្ររេដបូកជាតិនឹង ដោះស្រាយតែបញ្ហានៃការបាត់បង់ព្រៃឈើតែមួយ? ឬដោះស្រាយតែបញ្ហានៃការរេចរិលព្រៃឈើ? ឬដោះស្រាយតែបញ្ហានៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព? ឬដោះស្រាយតែបញ្ហានៃការអភិរក្ស? ឬដោះស្រាយតែបញ្ហានៃការបង្កើនបរិមាណកាបូនស្តុកនៅក្នុងព្រៃ? ឬដោះស្រាយនូវគ្រប់បញ្ហាទាំងអស់ខាងលើនេះ? តើការដោះស្រាយបញ្ហាទាំងនេះនឹងប្រែប្រួលទៅតាមពេលវេលាឬយ៉ាងណា? (ឧទាហរណ៍ៈ សកម្មភាពច្រើនទៀតនឹងត្រូវរួមបញ្ចូល? ឬការសម្រេចចិត្តទៅលើកម្មភាពបន្ថែមទៀត នឹងត្រូវពន្យារហូតដល់ទិន្នន័យមានគ្រប់គ្រាន់? តើកម្ពុជាគួរតែអនុវត្តយុទ្ធសាស្ត្រក្នុងកម្រិតណា? កម្រិតជាតិ? ឬចាប់ផ្តើមពីកម្រិតថ្នាក់ក្រោមជាតិជាបណ្តោះអាសន្ន (២០១៦-២០២០) មុនពេលឈានទៅដល់ការអនុវត្តកម្រិតថ្នាក់ជាតិ?

**២. បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ**

**ខ. សំនួរគោល៖** ផ្អែកលើបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ដែលបានកំណត់នៅក្នុងឯកសារជាតិនានា (ឧទាហរណ៍ៈ កម្មវិធីព្រៃឈើជាតិ(២០១០-២០២៩) ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ជលផល ផែនទីបង្ហាញផ្លូវរេដបូកជាតិ។ល។) តើបុព្វហេតុដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើអ្វីដែលយើងយកមកដោះស្រាយនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ? តើនៅក្នុងរយៈពេលខ្លី ពេលមធ្យម និងរយៈពេលវែង (ឧទាហរណ៍ៈ តាមរយៈជំហានៗ?) គួរតែមានបន្ថែមបុព្វហេតុដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើត្រូវរៀបចំ ឬ សិក្សាបន្ថែមទៀត ដើម្បីបន្ថែមទៅលើ ឬ ធ្វើបច្ចុប្បន្នភាពបុព្វហេតុដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ដែលបានកំណត់នៅក្នុងគោលនយោបាយ និងវិធានដែលមានស្រាប់?

**៣. គោលនយោបាយ និងវិធាន**

**គ.សំនួរគោល៖** ផ្អែកលើបុព្វហេតុដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើដែលនឹងដោះស្រាយ ថាតើគោលនយោបាយ និងវិធានដែលមានស្រាប់នៅក្នុង(ឧទាហរណ៍ៈ កម្មវិធីព្រៃឈើជាតិ (២០១០-២០២៩) ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ជលផល ផែនទីបង្ហាញផ្លូវរេដបូកជាតិ។ល។) ដែលបានស្នើឡើងនឹងយកមកដោះស្រាយឬទេ? តើគោលនយោបាយ និងវិធានគ្រប់គ្រង ឬ គោលនយោបាយ និងវិធានដែលមានស្រាប់អាចពង្រឹងតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិតាមរបៀបណា? តើនឹងត្រូវការគោលនយោបាយ និងវិធានបន្ថែមទៀតឬទេ? ប្រសិនបើត្រូវការតើគោលនយោបាយ និងវិធានអ្វីខ្លះ?

លទ្ធផលរំពឹងទុកនៃកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៣ (នឹងរៀបចំនៅថ្ងៃទី០៦-០៧ ខែកក្កដា ឆ្នាំ២០១៥ នៅខេត្តសៀមរាប)

យោងតាមលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី២ ជាមួយក្រុមអ្នកពាក់ព័ន្ធ និងផ្អែកតាមការសម្រេចចិត្តលើទំហំ និងបុព្វហេតុ ដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ព្រមទាំងការសម្រេចលើគោលនយោបាយ និងវិធានរេដបូក ប្រធានបទសំខាន់ដែលនឹងយកមកពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៣ មានដូចខាងក្រោមនេះ

**១. សកម្មភាព៖** បញ្ជាក់ពីសកម្មភាពរេដបូកដែលនឹងត្រូវអនុវត្ត និងទីកន្លែងណា ឬ វិសាលភាព

**ក. សំនួរគោល៖** តើសកម្មភាពអ្វីខ្លះដែលតម្រូវឲ្យអនុវត្ត ដើម្បីឆ្លើយតបនឹងគោលនយោបាយ និងវិធានជាអាទិភាព? ទាំងអតីតកាល បច្ចុប្បន្នកាល និងផែនការនាពេលខាងមុខ? តើសកម្មភាពអ្វីនឹងត្រូវអនុវត្ត ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រនេះ? តើសកម្មភាពទាំងនេះនឹងអនុវត្តនៅកន្លែងណា? នៅកម្រិតណា (ថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ តើសកម្មភាពមួយណាដែលមានឥទ្ធិពលលើដំណើការរៀបចំ Forest Reference Emission Level / Forest Reference Level ( FREL/FRL ) )

**២. ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និង FREL/FRL ៖** ការសម្រេចចិត្ត ឬ ការពិភាក្សាស្តីពីលទ្ធភាពត្រួតពិនិត្យ វាស់វែង ផ្ទៀងផ្ទាត់ និងលទ្ធភាពរាយការណ៍ពីសកម្មភាពដែលបានជ្រើសរើសសម្រាប់ការអនុវត្ត ព្រមទាំងកម្រិតបំភាយ យោង ដែលលទ្ធផលទាំងនេះនឹងត្រូវយកមកប្រៀបធៀប។

**ខ. សំនួរគោល៖** សម្រាប់ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ " តើត្រូវជ្រើសរើសសកម្មភាពណា សម្រាប់ការត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់?" ជាបន្ថែម ក្នុងន័យនៃ FREL/FRL "តើមានអ្វីខ្លះ និងត្រូវកំណត់ដោយរបៀបណា ទៅលើចំណុចសំខាន់ៗដែលត្រូវកំណត់ដូចជា៖ និយមន័យព្រៃឈើ ទំហំ ឬ វិសាលភាពថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ, ទំហំសកម្មភាព ប្រភេទនៃអាងស្តុកកាបូន ទិន្នន័យ វិធីសាស្ត្រ ពេលវេលា និងកម្រិតលំអៀង។ល។ នាពេលបច្ចុប្បន្ននេះ តើមានសមត្ថភាពបច្ចេកទេស និងស្ថាប័នណាខ្លះ និងនាពេលអនាគត តើមានសេចក្តីត្រូវការជំនាញអ្វីខ្លះ សម្រាប់ប្រទេសកម្ពុជា ដើម្បីបង្កើត និងប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិប្រកបដោយថាមពលនិងមានការទទួលខុសត្រូវខ្ពស់ និងអាចធ្វើបច្ចុប្បន្នភាពកម្រិតបំភាយយោងតាមពេលវេលាកំណត់?

**៣. ប្រព័ន្ធព័តមាននៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក** (Safeguards and Information System)

**គ. សំនួរគោល៖** តើតម្រូវការអ្វីខ្លះដែលគួរមាន ដើម្បីធានាថាប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន ត្រូវបានដោះស្រាយ និងគោរពនៅពេលដែលអនុវត្តសកម្មភាព គោលនយោបាយ និងវិធានរេដបូក? តើប្រទេសកម្ពុជានឹងធ្វើការត្រួតពិនិត្យ និងរាយការណ៍ស្តីពីការអនុវត្តគោលការណ៍ និងសន្ទស្សន៍នៃប្រព័ន្ធធានាសុវត្ថិភាពរេដបូកដោយរបៀបណា? តើប្រភេទព័តមានអ្វីខ្លះដែលប្រទេសកម្ពុជាចាំបាច់ត្រូវប្រមូល? តើមានតម្រូវការបច្ចេកទេស និងស្ថាប័ន និងជំហានអ្វីខ្លះដែលកម្ពុជាយើងត្រូវអនុវត្តតាម ដើម្បីបង្កើត និងប្រតិបត្តិ

ប្រព័ន្ធព័ត៌មាននៃប្រព័ន្ធធានាសុវត្ថិភាពប្រកបដោយការទទួលខុសត្រូវខ្ពស់? តើប្រព័ន្ធព័ត៌មាននៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក(SIS) ភ្ជាប់ជាមួយប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិដោយរបៀបណា?

**៤. ការបែងចែកការលើកទឹកចិត្ត ឬ ការចែករំលែកផលប្រយោជន៍**

**ឃ. សំនួរគោល៖** តើប្រភេទនៃការលើកទឹកចិត្ត ឬ ចែករំលែកផលប្រយោជន៍ ដែលទទួលបានពីការអនុវត្តសកម្មភាព គោលនយោបាយ ឬ វិធានរេដបូក មានអ្វីខ្លះ? តើការបែងចែកផលប្រយោជន៍នេះធ្វើឡើងដោយរបៀបណា? តើមានយន្តការអ្វីខ្លះដែលប្រទេសកម្ពុជានឹងប្រើដើម្បីធានាថាការបែងចែកផលប្រយោជន៍ពីការអនុវត្តរេដបូកនេះ មានប្រសិទ្ធិភាព ប្រសិទ្ធិផល និងសមធម៌? តើយន្តការដោះស្រាយទំនាស់របៀបណាដែលនឹងរៀបចំឡើង?

**កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៣**

**របៀបវារៈថ្ងៃទី១**

| ពេលវេលា | របៀបវារៈ | អ្នកសម្របសម្រួល/<br>អ្នកធ្វើបទបង្ហាញ |
|---|---|---|
| 08:00-08:30 | ការចុះឈ្មោះ | • លោក តេង ហួត |
| 08:30-09:00 | ពិធីបើកកិច្ចប្រជុំ<br>• គោរពភ្លេងជាតិ<br>• សុន្ទរកថាបើក | • លោក លន់ គឹមហ៊ី<br>• ប្រធានអង្គប្រជុំ |
| 09:00-09:15 | សេចក្តីផ្តើមកិច្ចប្រជុំ<br>• គោលបំណង របៀបវារៈ ភស្តុភារ និងការគាំទ្រ | • លោក លន់ គឹមហ៊ី |
| 09:15-09:30 | **សម្រាកអាហារសម្រន់** | |
| 09:30-10:15 | • សង្ខេបលទ្ធផលកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១<br>• សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ(ជំពូកទី៥ - ជំពូកទី៩)<br><u>សំណួរ និង ចម្លើយ</u> | • លោក ឈុន ឌីលុច |
| 10:15-11:00 | • ការណែនាំពីសំណួរពិភាក្សាដែលផ្តោតសំខាន់លើសកម្មភាពរេដបូកដែលត្រូវអនុវត្ត និងទីកន្លែងឬវិសាលភាព និងការបែងចែកក្រុមពិភាក្សា<br><u>សំណួរ និង ចម្លើយ</u> | • លោក ឈុន ឌីលុច |
| 11:00-12:00 | • ពិភាក្សាការងារជាក្រុម | • អ្នកសម្របសម្រួលក្រុម |
| 12:00-13:30 | **សំរាកអាហារថ្ងៃត្រង់** | |
| 13:30-14:30 | • បង្ហាញលទ្ធផលពិភាក្សាតាមក្រុម | • តំណាងក្រុម |

| | | |
|---|---|---|
| 14:30-15:15 | • ការណែនាំពីសំណួរពិភាក្សាដែលផ្តោតសំខាន់លើសកម្មភាពរេដបូកដែលត្រូវអនុវត្តសម្រាប់ ការត្រួតពិនិត្យ វាស់វែង ផ្ទៀងផ្ទាត់ និងរាយការណ៍កម្រិតបំភាយយោង និងការបែងចែកក្រុមពិភាក្សា<br>សំណួរ និង ចម្លើយ | • លោក ឈុន ឌីលុច |
| 15:15-15:30 | **សម្រាកអាហារសម្រន់** | |
| 15:30-16:30 | • ពិភាក្សាការងារជាក្រុម | • អ្នកសម្របសម្រួលក្រុម |
| 16:30-17:15 | • បង្ហាញលទ្ធផលពិភាក្សាតាមក្រុម | • តំណាងក្រុម |
| 17:15-17:30 | បូកសរុបលទ្ធផលកិច្ចប្រជុំថ្ងៃទី១និងរាយការណ៍ជូនអង្គប្រជុំ | • លោក លន់ គឹមហ៊ី |
| 17:30 | **សម្រាក** | |

## របៀបវារៈថ្ងៃទី២

| | | |
|---|---|---|
| 08:30-09:30 | • ការណែនាំពីសំណួរពិភាក្សាដែលផ្តោតសំខាន់លើតម្រូវការដើម្បីធានាថាប្រព័ន្ធធានាសុវត្ថិភាពសង្គម-បរិស្ថាន ត្រូវបានដោះស្រាយនិងគោរពនៅពេលអនុវត្តសកម្មភាពរេដបូក និងការបែងចែកក្រុមពិភាក្សា<br>សំណួរ និង ចម្លើយ | • លោក ឈុន ឌីលុច |
| 09:30-10:30 | • ពិភាក្សាការងារជាក្រុម | • អ្នកសម្របសម្រួលក្រុម |
| 10:30-10:45 | **សំរាកអាហារសម្រន់** | |
| 10:45-12:00 | • បង្ហាញលទ្ធផលពិភាក្សាតាមក្រុម | • តំណាងក្រុម |
| 12:00-13:30 | **សំរាកអាហារថ្ងៃត្រង់** | |
| 13:30-14:15 | • ការណែនាំពីសំណួរពិភាក្សាដែលផ្តោតសំខាន់លើប្រភេទនៃការចែករំលែកផលប្រយោជន៍ ដែលទទួលបានពីការអនុវត្តសកម្មភាពរេដបូក និងការបែងចែកក្រុមពិភាក្សា<br>សំណួរ និង ចម្លើយ | • លោក ឈុន ឌីលុច |
| 14:15-15:15 | • ពិភាក្សាការងារជាក្រុម | • អ្នកសម្របសម្រួលក្រុម |
| 15:15-15:30 | **សំរាកអាហារសម្រន់** | |
| 15:30-16:30 | • បង្ហាញលទ្ធផលពិភាក្សាតាមក្រុម | • តំណាងក្រុម |
| 16:30-16:45 | • ផែនការបន្តសម្រាប់កិច្ចពិភាក្សាយោបល់រេដបូកនៅថ្នាក់ក្រោមជាតិ | • លោក ឈុន ឌីលុច |
| 16:45-17:15 | • បូកសរុបលទ្ធផលកិច្ចប្រជុំថ្ងៃទី១និងរាយការណ៍ជូនអង្គប្រជុំ | • លោក លន់ គឹមហ៊ី |
| 17:15-17:30 | សុន្ទរកថាបិទកិច្ចប្រជុំ | |

| | | |
|---|---|---|
| 17:30 | **សម្រាក** | |